ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អ អ ក

EAC

អាជ្ញាធរអគ្គិសនីកម្ពុជា

លេខ០៣៧ ៧/២០ អអក

# សេចក្តីសម្រេច
# ស្តីពីការកំណត់បញ្ជីថ្លៃលក់អគ្គិសនីសម្រាប់ អ្នកប្រើប្រាស់អគ្គិសនីធុនធំ និងធុនមធ្យម "ប្រភេទឧស្សាហកម្ម និងកសិកម្ម" និង "ប្រភេទពាណិជ្ជកម្ម រដ្ឋបាល និងផ្សេងៗ" ដែលទិញអគ្គិសនីពីបណ្តាញបញ្ជូនរង និងបណ្តាញចែកចាយរបស់អគ្គិសនីកម្ពុជា ទទួលប្រភពអគ្គិសនីនាំចូលពីប្រទេសវៀតណាម ចំនួន ៦ ខេត្ត សម្រាប់ឆ្នាំ២០២០

## អាជ្ញាធរអគ្គិសនីកម្ពុជា

- បានឃើញព្រះរាជក្រម លេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យ លេខ ០៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ស្តីពីគោលការណ៍វាយតម្លៃភាពត្រឹមត្រូវនៃចំណាយក្នុងអាជីវកម្មអគ្គិសនី
- ប្រកាសរបស់ក្រសួងរ៉ែ និងថាមពល លេខ០០៤០ រថ.អវថ.ប្រក ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០ ស្តីពីការដាក់ឲ្យអនុវត្តផែនការបន្ថយថ្លៃលក់អគ្គិសនីឲ្យអ្នកប្រើប្រាស់ និងផែនការកែទម្រង់ការបង់ថ្លៃអគ្គិសនីរបស់អ្នកប្រើប្រាស់សម្រាប់ឆ្នាំ២០២០ និងឆ្នាំ២០២១
- យោងអាជ្ញាបណ្ណ លេខ០០១.ឯអ ដែលបានចេញឲ្យអគ្គិសនីកម្ពុជា នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០២
- យោងការពិគ្រោះយោបល់សាធារណៈពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ ដល់ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០២០
- យោងការសម្រេចនៃសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជាលើកទី៣៥៤ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០២០

## សម្រេច

### ប្រការ១

កំណត់បញ្ជីថ្លៃលក់អគ្គិសនីឲ្យ **អគ្គិសនីកម្ពុជា** ដែលបន្ទាប់ពីនេះទៅហៅថា "អ្នកលក់" លក់អគ្គិសនីឲ្យ **អ្នកប្រើប្រាស់អគ្គិសនី** ដែលបន្ទាប់ពីនេះទៅហៅថា "អ្នកទិញ" ដែលទិញអគ្គិសនីធុនធំ និងធុនមធ្យម "ប្រភេទឧស្សាហកម្ម និងកសិកម្ម" និង"ប្រភេទពាណិជ្ជកម្ម រដ្ឋបាល និងផ្សេងៗ" ពីបណ្តាញបញ្ជូនរង និងបណ្តាញចែកចាយរបស់អគ្គិសនីកម្ពុជា ដែលទទួលប្រភពអគ្គិសនីនាំចូលពីប្រទេសវៀតណាម តាមខ្សែបណ្តាញ ២២kV និង ៣៥kV ចំនួន ៦ ខេត្ត មាននៅស្រុកពញាក្រែក និងស្រុកមេមត់ ខេត្តត្បូងឃ្មុំ, ស្រុកស្នួល ខេត្តក្រចេះ, ស្រុកកែវសីមា ខេត្តមណ្ឌលគិរី, ក្រុងបានលុង ខេត្តរតនគិរី, ស្រុកកំពង់ត្រាច ខេត្តកំពត និងនៅខេត្តស្វាយរៀង សម្រាប់ឆ្នាំ២០២០ ទៅតាមប្រភេទអ្នកប្រើប្រាស់ លក្ខខណ្ឌភ្ជាប់ និងអត្រាថ្លៃលក់អគ្គិសនី ដូចខាងក្រោម ៖

| ប្រភេទអ្នកប្រើប្រាស់ និងលក្ខខណ្ឌផ្សេងៗ | ឯកតា | អត្រាថ្លៃលក់ |
|---|---|---|
| **១. អ្នកប្រើប្រាស់ឧស្សាហកម្ម និងកសិកម្មភ្ជាប់ពីខ្សែបណ្តាញតង់ស្យុងមធ្យម៖** | | |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម | $/kWh | 0.1370 |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 5.00 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកច្រើន (៧ព្រឹកដល់៩យប់) | $/kWh | 0.1300 |
| ៣. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកតិច (៩យប់ដល់៧ព្រឹក) | $/kWh | 0.1100 |
| ➢ ចំពោះអ្នកប្រើប្រាស់មានដាក់តម្លើងប្រភពពន្លឺព្រះអាទិត្យ | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 5.00 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពល (២៤ម៉ោង) | $/kWh | 0.1300 |
| **២. អ្នកប្រើប្រាស់ប្រភេទពាណិជ្ជកម្ម រដ្ឋបាល និងផ្សេងៗភ្ជាប់ពីខ្សែបណ្តាញតង់ស្យុងមធ្យម ៖** | | |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម | $/kWh | 0.1580 |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 5.80 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកច្រើន (៧ព្រឹកដល់៩យប់) | $/kWh | 0.1500 |
| ៣. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកតិច (៩យប់ដល់៧ព្រឹក) | $/kWh | 0.1240 |
| ➢ ចំពោះអ្នកប្រើប្រាស់មានដាក់តម្លើងប្រភពពន្លឺព្រះអាទិត្យ | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 5.80 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពល (២៤ម៉ោង) | $/kWh | 0.1500 |
| **៣. អ្នកប្រើប្រាស់ឧស្សាហកម្ម និងកសិកម្មភ្ជាប់ពីក្រោមត្រង់ស្វូចែកចាយតាមកុងទ័រ LV (ត្រង់ស្វូផ្ទាល់ខ្លួន )៖** | | |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម | $/kWh | 0.14248 |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 5.00 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកច្រើន (៧ព្រឹកដល់៩យប់) | $/kWh | 0.13520 |
| ៣. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកតិច (៩យប់ដល់៧ព្រឹក) | $/kWh | 0.11440 |
| ➢ ចំពោះអ្នកប្រើប្រាស់មានដាក់តម្លើងប្រភពពន្លឺព្រះអាទិត្យ | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 5.00 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពល (២៤ម៉ោង) | $/kWh | 0.1352 |



**អាជ្ញាធរអគ្គិសនីកម្ពុជា** ៖ ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០២៣ ២១៧ ៦៥៤ / ៩៨៧ ៩៩៨ ទូរសារ ៖ ០២៣ ២១៤ ១៤៤, អ៊ីម៉ែល ៖ admin@eac.gov.kh ; Website : www.eac.gov.kh

| | | |
|---|---|---|
| **ចំពោះអ្នកសុំឲ្យអ្នកផ្គត់ផ្គង់វិនិយោគគ្រប់ស្នូឲ្យខ្លួន ៖** | | |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម | $/kWh | 0.15048 |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 5.00 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកច្រើន (៧ព្រឹកដល់៩យប់) | $/kWh | 0.14320 |
| ៣. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកតិច (៩យប់ដល់៧ព្រឹក) | $/kWh | 0.12240 |
| ➢ ចំពោះអ្នកប្រើប្រាស់មានដាក់តម្លើងប្រភពពន្លឺព្រះអាទិត្យ | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 5.00 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពល (២៤ម៉ោង) | $/kWh | 0.1432 |
| **៤. អ្នកប្រើប្រាស់ប្រភេទពាណិជ្ជកម្ម រដ្ឋបាល និងផ្សេងៗភ្ជាប់ពីក្រោមត្រង់ស្វូចែកចាយតាមកុងទ័រ LV (ត្រង់ស្វូផ្ទាល់ខ្លួន)៖** | | |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម | $/kWh | 0.16432 |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 5.80 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកច្រើន (៧ព្រឹកដល់៩យប់) | $/kWh | 0.15600 |
| ៣. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកតិច (៩យប់ដល់៧ព្រឹក) | $/kWh | 0.12896 |
| ➢ ចំពោះអ្នកប្រើប្រាស់មានដាក់តម្លើងប្រភពពន្លឺព្រះអាទិត្យ | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 5.80 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពល (២៤ម៉ោង) | $/kWh | 0.1560 |
| **ចំពោះអ្នកសុំឲ្យអ្នកផ្គត់ផ្គង់វិនិយោគគ្រប់ស្នូឲ្យខ្លួន ៖** | | |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម | $/kWh | 0.17232 |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 5.80 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកច្រើន (៧ព្រឹកដល់៩យប់) | $/kWh | 0.16400 |
| ៣. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកតិច (៩យប់ដល់៧ព្រឹក) | $/kWh | 0.13696 |
| ➢ ចំពោះអ្នកប្រើប្រាស់មានដាក់តម្លើងប្រភពពន្លឺព្រះអាទិត្យ | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 5.80 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពល (២៤ម៉ោង) | $/kWh | 0.1640 |

**ប្រការ២**

ពិតមែនតែអត្រាថ្លៃអគ្គិសនីដែលកំណត់ក្នុងប្រការ ១ ខាងលើ បានកំណត់ជាប្រាក់ដុល្លារសហរដ្ឋអាមេរិក ប៉ុន្តែ "អ្នកទិញ" ប្រភេទឧស្សាហកម្ម និងកសិកម្ម និងប្រភេទពាណិជ្ជកម្ម រដ្ឋបាល និងផ្សេងៗ អាចធ្វើការទូទាត់ថ្លៃអគ្គិសនីជូន "អ្នកលក់" ជាប្រាក់រៀល ដោយគិតតាមអត្រាប្តូរប្រាក់ផ្លូវការដែល"អ្នកលក់"

កំណត់លើមូលដ្ឋាននៃអត្រាប្តូរប្រាក់មធ្យមរបស់ធនាគារជាតិនៃកម្ពុជា និងអត្រាប្តូរប្រាក់នៅលើទីផ្សារពីថ្ងៃទី២១ ដល់ថ្ងៃចុងខែ មុនថ្ងៃធ្វើវិក្កយបត្រ ។

**ប្រការ៣**

ការអនុវត្តអត្រាថ្លៃលក់អគ្គិសនី តាមប្រភេទអ្នកប្រើប្រាស់ និងលក្ខខណ្ឌ ដែលមានចែងក្នុងប្រការ ១ ខាងលើ ត្រូវគោរពទៅតាមសេចក្តីណែនាំលម្អិត ក្នុងឧបសម្ព័ន្ធដែលភ្ជាប់ជាមួយសេចក្តីសម្រេចនេះ ។

**ប្រការ៤**

បញ្ជីថ្លៃលក់អគ្គិសនីកំណត់ក្នុងប្រការ ១ ខាងលើ អនុវត្តចំពោះតែ "អ្នកទិញ" ដែលមានទីតាំងឋិតនៅក្នុងដែនអាជ្ញាបណ្ណចែកចាយរបស់ "អ្នកលក់" ចំនួន ៦ ខេត្ត មាននៅស្រុកពញាក្រែក និងស្រុកមេមត់ ខេត្តត្បូងឃ្មុំ, ស្រុកស្នួល ខេត្តក្រចេះ, ស្រុកកែវសីមា ខេត្តមណ្ឌលគិរី, ក្រុងបានលុង ខេត្តរតនគិរី, ស្រុកកំពង់ត្រាច ខេត្តកំពត និងនៅខេត្តស្វាយរៀង ប៉ុណ្ណោះ ។

**ប្រការ៥**

បញ្ជីថ្លៃលក់អគ្គិសនីថ្មី ក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តចំពោះបរិមាណថាមពលប្រើប្រាស់ចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២០ តទៅ រហូតដល់មានការកែសម្រួលឡើងវិញ ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ស្របតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។ បញ្ជីថ្លៃលក់អគ្គិសនីពាក់ព័ន្ធ ដែលបានដាក់ឲ្យប្រើប្រាស់មុនសេចក្តីសម្រេចនេះ ត្រូវនិរាករណ៍ ចាប់ពីពេលអនុវត្តបញ្ជីថ្លៃលក់អគ្គិសនីថ្មីនេះ តទៅ ។

**ប្រការ៦**

"អ្នកលក់" និង "អ្នកទិញ" ដូចមានក្នុងប្រការ១ ខាងលើ មានភារកិច្ចអនុវត្តបញ្ជីថ្លៃលក់អគ្គិសនីថ្មីនេះឲ្យមានប្រសិទ្ធភាព។

**ប្រការ៧**

"អ្នកលក់" មានភារកិច្ចផ្សព្វផ្សាយអំពីខ្លឹមសារនៃសេចក្តីសម្រេចនេះ ដល់អតិថិជនរបស់ខ្លួន គ្រប់ប្រភេទដែលមានការពាក់ព័ន្ធ។

ថ្ងៃអង្គារ ៣កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**យឹម វិសិដ្ឋ**

<u>ចម្លងជូន ៖</u>

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរ៉ែ និងថាមពល

-សាលាខេត្តពាក់ព័ន្ធ

-មន្ទីររ៉ែ និងថាមពល ខេត្តពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

- អគ្គិសនីកម្ពុជា

"ដើម្បីអនុវត្ត និងផ្សព្វផ្សាយ"

-ឯកសារ-កាលប្បវត្តិ

**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ,
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh

# ឧបសម្ព័ន្ធ

## សេចក្តីណែនាំក្នុងការអនុវត្តបញ្ជីថ្លៃលក់អគ្គិសនីសម្រាប់អ្នកប្រើប្រាស់អគ្គិសនីធុនធំ និងធុនមធ្យម "ប្រភេទឧស្សាហកម្ម និងកសិកម្ម" និង "ប្រភេទពាណិជ្ជកម្ម រដ្ឋបាល និងផ្សេងៗ" ដែលទិញអគ្គិសនីពីបណ្តាញបញ្ជូនរង និងបណ្តាញចែកចាយរបស់អគ្គិសនីកម្ពុជា ទទួលប្រភពអគ្គិសនីនាំចូលពីប្រទេសវៀតណាម ចំនួន ៦ ខេត្ត សម្រាប់ឆ្នាំ២០២០

### ១-សេចក្តីណែនាំលម្អិតក្នុងការកំណត់លក្ខខណ្ឌសំខាន់ៗ សម្រាប់កំណត់ប្រភេទអ្នកប្រើប្រាស់ធុនធំ និងធុនមធ្យម ប្រភេទឧស្សាហកម្ម និងកសិកម្ម" និង "ប្រភេទពាណិជ្ជកម្ម រដ្ឋបាល និងផ្សេងៗ" ក្នុងអត្រាថ្លៃលេខរៀងទី១ ទី២ ទី៣ និងទី៤

លក្ខខណ្ឌសំខាន់ៗ សម្រាប់កំណត់ប្រភេទនៃអ្នកប្រើប្រាស់ធុនធំ និងធុនមធ្យម ប្រភេទឧស្សាហកម្ម និងកសិកម្ម" និង "ប្រភេទពាណិជ្ជកម្ម រដ្ឋបាល និងផ្សេងៗ" មានដូចខាងក្រោម ៖

*អតិថិជនធុនមធ្យម ទិញពីនាឡិកាស្ទង់តង់ស្យុងទាប ដាក់ក្រោមត្រង់ស្វូចែកចាយរបស់អគ្គិសនីកម្ពុជា និងដាក់ក្រោមត្រង់ស្វូចែកចាយដែលខ្លួនបានវិនិយោគ*

*លក្ខខណ្ឌភ្ជាប់បណ្តាញ ៖* អតិថិជនធុនមធ្យមដែលទិញអគ្គិសនីពីនាឡិកាស្ទង់តង់ស្យុងទាបដាក់ក្រោមត្រង់ស្វូចែកចាយរបស់អគ្គិសនីកម្ពុជា គឺជាអតិថិជន ដែលភ្ជាប់ចរន្តពីបន្ទប់ត្រង់ស្វូផ្ទាល់ ដោយដាក់នាឡិកាស្ទង់ នៅក្រោមទ្វារចរន្តតង់ស្យុងទាបនៃត្រង់ស្វូចែកចាយក្នុងបន្ទប់ចែកចាយ ឬនៃត្រង់ស្វូចែកចាយលើបង្គោល ដែលវិនិយោគសាងសង់ដោយអគ្គិសនីកម្ពុជា ។ អតិថិជនធុនមធ្យមដែលទិញអគ្គិសនីពីនាឡិកាស្ទង់តង់ស្យុងទាប ដាក់ក្រោមត្រង់ស្វូចែកចាយដែលខ្លួនវិនិយោគ គឺជាអតិថិជនដែលភ្ជាប់ចរន្តពីបន្ទប់ត្រង់ស្វូផ្ទាល់ ដោយដាក់នាឡិកាស្ទង់នៅក្រោមទ្វារចរន្តតង់ស្យុងទាប នៃត្រង់ស្វូចែកចាយក្នុងបន្ទប់ចែកចាយ ឬនៃត្រង់ស្វូចែកចាយលើបង្គោល ដែលវិនិយោគសាងសង់ដោយខ្លួនឯងផ្ទាល់ ។ ចំពោះអតិថិជនធុនមធ្យមទាំងពីរប្រភេទនេះអានុភាពចុះកិច្ចសន្យាផ្គត់ផ្គង់អគ្គិសនីចាប់ពី ១០០ kVA ដល់ ២៧៥ kVA (ការ៉េអា)។

*លក្ខខណ្ឌប្រើប្រាស់ ៖* មិនមានការកំណត់លក្ខខណ្ឌប្រើប្រាស់អប្បបរមាឡើយ។

*អតិថិជនធុនធំ ដែលទិញអគ្គិសនីពីនាឡិកាស្ទង់ ដែលដាក់នៅផ្នែកតង់ស្យុងមធ្យម*

*លក្ខខណ្ឌភ្ជាប់បណ្តាញ ៖* អតិថិជនធុនធំដែលទិញពីនាឡិកាស្ទង់ ដែលដាក់នៅផ្នែកតង់ស្យុងមធ្យម គឺជាអតិថិជន ដែលភ្ជាប់ចរន្តផ្ទាល់ពីបណ្តាញតង់ស្យុងមធ្យមរបស់អគ្គិសនីកម្ពុជា ។ អតិថិជនអាចមានបន្ទប់ត្រង់ស្វូ ឬត្រង់ស្វូលើបង្គោលភ្ជាប់លើបណ្តាញតង់ស្យុងមធ្យមរបស់អគ្គិសនីកម្ពុជា ដោយដាក់នាឡិកាស្ទង់នៅផ្នែកតង់ស្យុងមធ្យម ។ អតិថិជនក៏អាចភ្ជាប់ចរន្តពីបណ្តាញតង់ស្យុងមធ្យម ហើយយកចរន្តតង់ស្យុងមធ្យមនេះ ទៅកាន់ទីតាំងរបស់ខ្លួន ដោយបង្កើតជាប្រព័ន្ធចែកចាយដោយ



អាជ្ញាធរអគ្គិសនីកម្ពុជា : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្តាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៥៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh

ខ្សែករបស់ខ្លួន ដែលមានត្រង់ស្វូចែកចាយច្រើននៅក្នុងទីតាំងប្រើប្រាស់របស់ខ្លួនបានដែរ ។

*លក្ខខណ្ឌប្រើប្រាស់ ៖* មិនមានការកំណត់លក្ខខណ្ឌប្រើប្រាស់អប្បបរមាឡើយ។

## ២-សេចក្តីណែនាំសម្រាប់ការទូទាត់ថ្លៃប្រើប្រាស់អគ្គិសនី សម្រាប់អ្នកទិញ ក្នុងអត្រាថ្លៃលេខរៀងទី១ ទី២ ទី៣ និងទី៤

ក្នុងការកំណត់ថ្លៃលក់អគ្គិសនី សម្រាប់អ្នកទិញ ក្នុងអត្រាថ្លៃលេខរៀងទី១ ទី២ ទី៣ និងទី៤ ដូចមានក្នុងប្រការ១ នៃសេចក្តីសម្រេចខាងលើ ត្រូវបានកំណត់ជាប្រាក់ដុល្លារអាមេរិក ហើយអ្នកទិញអាចទូទាត់ជាប្រាក់រៀល ដោយគិតតាមអត្រាប្តូរប្រាក់ផ្លូវការ ដែលអ្នកលក់កំណត់លើមូលដ្ឋាននៃអត្រាប្តូរប្រាក់មធ្យមរបស់ធនាគារជាតិនៃកម្ពុជា និងអត្រាប្តូរប្រាក់ផ្លូវការលើទីផ្សារពីថ្ងៃទី២១ ដល់ថ្ងៃចុងខែ មុនថ្ងៃធ្វើវិក្កយបត្រ ។ ក្នុងករណីនេះ ហានិភ័យនៃអត្រាប្តូរប្រាក់ ប្រសិនបើមានការប្រែប្រួល គឺអ្នកទិញ ជាអ្នកទទួលបន្ទុក ។

## ៣-សេចក្តីណែនាំសម្រាប់អនុវត្តអត្រាថ្លៃលក់អគ្គិសនី សម្រាប់អ្នកទិញ ក្នុងអត្រាថ្លៃលេខរៀងទី១ ទី២ ទី៣ និងទី៤ ដែលមានតម្លើងប្រព័ន្ធពន្លឺព្រះអាទិត្យភ្ជាប់សាំងក្រូនជាមួយប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីរបស់អ្នកលក់

សម្រាប់អ្នកទិញដែលបិតក្នុងអត្រាថ្លៃលេខរៀងទី១ ទី២ ទី៣ និងទី៤ ដែលមានតម្លើងប្រព័ន្ធពន្លឺព្រះអាទិត្យភ្ជាប់សាំងក្រូនជាមួយប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី" ទាំងអតិថិជនចាស់ និងទាំងអតិថិជនថ្មី គឺពុំមានជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម និងជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាពទេ គឺត្រូវអនុវត្ត "បញ្ជីថ្លៃលក់អគ្គិសនីសម្រាប់អ្នកប្រើប្រាស់មានដាក់តម្លើងប្រភពពន្លឺព្រះអាទិត្យ" ដែលមានកំណត់ក្នុងប្រការ ១ ខាងលើ ។

ចំពោះអ្នកទិញ ដែលមានតម្លើងប្រព័ន្ធពន្លឺព្រះអាទិត្យភ្ជាប់សាំងក្រូនជាមួយប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីបណ្តាញជាតិ និងមានការអនុញ្ញាតពីអ្នកលក់នោះ "បញ្ជីថ្លៃលក់អគ្គិសនីសម្រាប់អ្នកប្រើប្រាស់មានដាក់តម្លើងប្រភពពន្លឺព្រះអាទិត្យ" ដែលមានកំណត់ក្នុងប្រការ ១ ខាងលើ នឹងត្រូវជំនួសសេចក្តីសម្រេចចាស់របស់អាជ្ញាធរអគ្គិសនីកម្ពុជា លេខ ៣៩៥.សរ.១៨.អអក ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកំណត់បញ្ជីថ្លៃលក់អគ្គិសនីសម្រាប់អ្នកផ្គត់ផ្គង់អគ្គិសនីលក់ឲ្យអ្នកប្រើប្រាស់ធុនធំ និងធុនធំ ដែលមានតម្លើងប្រព័ន្ធពន្លឺព្រះអាទិត្យ ភ្ជាប់សាំងក្រូនជាមួយប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីរបស់បណ្តាញជាតិ សម្រាប់ការប្រើប្រាស់អគ្គិសនីផ្ទាល់ខ្លួន ។

## ៤-សេចក្តីណែនាំសម្រាប់អនុវត្តអត្រាថ្លៃលក់អគ្គិសនី សម្រាប់អ្នកទិញ ក្នុងអត្រាថ្លៃលេខរៀងទី១ ទី២ ទី៣ និងទី៤ ដែលពុំមានតម្លើងប្រព័ន្ធពន្លឺព្រះអាទិត្យភ្ជាប់សាំងក្រូនជាមួយប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីរបស់អ្នកលក់

សម្រាប់អ្នកទិញដែលមានអត្រាថ្លៃក្នុងលេខរៀងទី១ ទី២ ទី៣ និងទី៤ ដែលមិនមានតម្លើងប្រព័ន្ធពន្លឺព្រះអាទិត្យ ត្រូវបានផ្តល់ជម្រើស ចំនួន២ គឺ ១.ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម ឬ ២.ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព ។

បន្ទាប់ពី អាជ្ញាធរអគ្គិសនីកម្ពុជាចេញសេចក្តីសម្រេចថ្មីខាងលើនេះ អ្នកលក់ត្រូវជូនដំណឹងទៅអ្នកទិញរបស់ខ្លួន អំពីខ្លឹមសារនៃសេចក្តីសម្រេចថ្មីនេះ ហើយអ្នកទិញត្រូវជូនដំណឹងទៅអ្នកលក់វិញ អំពីការជ្រើសរើសរបស់ខ្លួន តាមលិខិតជាលាយលក្សណ៍អក្សរក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹង ។ ប្រសិនបើអ្នកទិញពុំបានជូនដំណឹងក្នុងរយៈពេលកំណត់ខាងលើទេ ចាត់ទុកថាអ្នកទិញជ្រើសរើស "ការបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម" បន្តទៀត ។

### ៤.១-លក្ខខណ្ឌសម្រាប់អនុវត្តជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម

សម្រាប់អ្នកទិញដែលមានអត្រាថ្លៃក្នុងលេខរៀងទី១ ទី២ ទី៣ និងទី៤ ដែលមិនមានតម្លើងប្រព័ន្ធពន្លឺព្រះអាទិត្យ ជ្រើសរើសយកបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម គឺត្រូវអនុវត្តតាមអត្រាថ្លៃលក់ដែលមានកំណត់ក្នុងប្រការ ១ ខាងលើ និងលក្ខខណ្ឌនៃការភ្ជាប់ ដែលមានកំណត់ក្នុងសេចក្តីណែនាំលម្អិតនេះ ។ អ្នកទិញក្នុងប្រភេទនេះគឺបង់ថ្លៃប្រើប្រាស់អគ្គិសនីរបស់ខ្លួន ទៅតាមបរិមាណអគ្គិសនីប្រចាំខែ គិតជាគីឡូវ៉ាត់ម៉ោង គុណនឹងអត្រាថ្លៃលក់ថាមពល ប៉ុណ្ណោះ ដែលមានកំណត់ក្នុងប្រកាស ១ ខាងលើ ។ ប្រសិនបើអ្នកទិញចង់ប្តូរពី "ការបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម" ទៅជ្រើសរើស "ការបង់ថ្លៃលក់អគ្គិសនីតាមពេលវេលា និងអានុភាព" វិញ អ្នកទិញ ត្រូវស្នើសុំទៅអ្នកលក់អំពីការជ្រើសរើស "ការបង់ថ្លៃលក់អគ្គិសនីតាមពេលវេលា និងអានុភាព" ហើយអ្នកលក់ត្រូវពិនិត្យរៀបចំឲ្យអ្នកទិញអនុវត្តជម្រើស "ការបង់ថ្លៃលក់អគ្គិសនីតាមពេលវេលា និងអានុភាព" តាមការស្នើសុំរបស់អ្នកទិញ។

### ៤.២-លក្ខខណ្ឌសំខាន់ៗសម្រាប់អនុវត្តជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព

១.អត្រាថ្លៃអានុភាព (Capacity Charge) គិតជាដុល្លារអាមេរិក ក្នុង១គីឡូវ៉ាត់ ក្នុង១ខែ ផ្អែកលើទំហំអានុភាពនៃកិច្ចសន្យា គិតជាគីឡូវ៉ាត់ (kW) ។ ទំហំអានុភាពនៃកិច្ចសន្យា គឺជាអានុភាពដែលស្នើសុំដោយអ្នកទិញ និងទទួលការយល់ព្រមពីអ្នកលក់ ដោយមានបញ្ជាក់ក្នុងកិច្ចព្រមព្រៀងទិញ-លក់អគ្គិសនី ។ ទំហំអានុភាពនៃកិច្ចសន្យា អាចខុសពីទំហំអានុភាពតម្លើងសរុបរបស់ត្រង់ស្វូ ។ ក្នុងដំណាក់កាលដំបូង អ្នកទិញអាចស្នើសុំកែសម្រួលទំហំអានុភាពនៃកិច្ចសន្យា (Contracted Capacity) បាន ហើយអ្នកលក់ត្រូវពិនិត្យលើសំណើសុំរបស់អ្នកទិញ ដើម្បីកំណត់ទំហំអានុភាពនៃកិច្ចសន្យា (Contracted Capacity) ថ្មី ដោយផ្អែកលើស្ថានភាពជាក់ស្តែង ។ ក្នុងរយៈពេល ១ (មួយ) ឆ្នាំ បន្ទាប់ពីបានកំណត់ទំហំអានុភាពនៃកិច្ចសន្យា អ្នកទិញពុំអាចបន្ថយទំហំអានុភាពនៃកិច្ចសន្យា (Contracted Capacity) បានទេ ។ ក្នុងករណីអ្នកទិញចង់តម្លើងទំហំអានុភាពនៃកិច្ចសន្យា (Contracted Capacity) អ្នកទិញត្រូវ

ដាក់ពាក្យស្នើសុំជាលាយលក្ខណ៍អក្សរទៅអ្នកលក់ ហើយអ្នកលក់ត្រូវពិនិត្យសំណើសុំ និងត្រូវឆ្លើយតបទៅអ្នកទិញ តើខ្លួនមានអានុភាពអាច ផ្តល់ឲ្យអ្នកទិញបាន ឬពុំបាន ។

២.អត្រាថ្លៃថាមពល (Energy Charge) គិតជាដុល្លារអាមេរិក ក្នុង១គីឡូវ៉ាត់ម៉ោង ផ្អែកលើបរិមាណថាមពល ដែលប្រើប្រាស់តាមពេលវេលា គឺ ១.ក្នុងពេលមានបន្ទុកច្រើន ពីម៉ោង 07:00 ព្រឹក ដល់ម៉ោង 21:00 យប់ និង២.ក្នុងពេលមានបន្ទុកតិច ពីម៉ោង 21:00 យប់ ដល់ម៉ោង 07:00 ព្រឹក ។

៣.ចំពោះអ្នកទិញ ដែលកំពុងអនុវត្តបញ្ជីថ្លៃអគ្គិសនីតាមពេលវេលា តាមសេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជាលេខ ០៤៧.សរ.១៧.អអក ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ ត្រូវបានផ្តល់ជម្រើសបង់ថ្លៃអគ្គិសនីថ្មី ចំនួន ២ គឺ ១."ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម" ឬ ២."ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព" ។ បន្ទាប់ពី អាជ្ញាធរអគ្គិសនីកម្ពុជាចេញសេចក្តីសម្រេចថ្មីខាងលើនេះ អ្នកលក់ត្រូវចេញវិក្កយបត្រថ្លៃអគ្គិសនីឲ្យអ្នកទិញខាងលើតាម "ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព" ស្របតាមសេចក្តីសម្រេចថ្មីនេះ ជាបណ្តោះអាសន្នសិន ដោយភ្ជាប់ជាមួយច្បាប់ចម្លងសេចក្តីសម្រេចស្តីពីបញ្ជីថ្លៃលក់ថ្មីនេះ ។ ប្រសិនបើ អ្នកទិញមានបំណងចង់ផ្លាស់ប្តូរមកប្រើប្រាស់ "ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម" វិញ អ្នកទិញត្រូវស្នើសុំទៅអ្នកលក់តាមលិខិតជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃចេញវិក្កយបត្រថ្លៃអគ្គិសនីថ្មី ។ បន្ទាប់ពីទទួលលិខិតស្នើសុំពីអ្នកទិញ អ្នកលក់ត្រូវកែតម្រូវវិក្កយបត្រថ្លៃអគ្គិសនីដែលចេញរួចហើយនោះ ពី "ការបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព" ទៅ "ការបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម" វិញ និងបន្តអនុវត្តអត្រាថ្លៃមធ្យមសម្រាប់ការចេញវិក្កយបត្រថ្លៃអគ្គិសនីឲ្យអ្នកទិញនៅខែបន្ទាប់ តទៅ ។ ក្នុងករណីអ្នកទិញពុំបានស្នើសុំទៅអ្នកលក់តាមលិខិតជាលាយលក្ខណ៍អក្សរ ក្នុងរយៈពេលកំណត់ខាងលើទេ ចាត់ទុកថា អ្នកទិញជ្រើសរើស "ការបង់ថ្លៃលក់អគ្គិសនីតាមពេលវេលា និងអានុភាព" ។ ទន្ទឹមនឹងនេះ ចំពោះអ្នកទិញជ្រើសរើស "ការបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព" រួចហើយ អ្នកទិញនោះពុំអាចប្តូរមកជ្រើសរើស "ការបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម" វិញបានទេ ។

៤.ចំពោះអ្នកទិញដែលអនុវត្ត "ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព" នាឡិកាស្ទង់នឹងកត់ត្រាតម្រូវការការប្រើប្រាស់ខ្ពស់បំផុតរៀងរាល់ ១៥ នាទីម្តង ក្នុងខួបស្រង់ថាមពល ។ ប្រសិនបើការកត់ត្រានោះបង្ហាញថា តម្រូវការការប្រើប្រាស់ខ្ពស់បំផុត ខ្ពស់ជាងទំហំអានុភាពនៃកិច្ចសន្យានោះ អ្នកទិញត្រូវបង់ការពិន័យអត្រាថ្លៃអានុភាព (Capacity Charge) ស្មើនឹង ២ ដង នៃអត្រាថ្លៃអានុភាពធម្មតា ចំពោះអានុភាពដែលលើស សម្រាប់ខួបស្រង់ថាមពលនោះ ។

## ៦-លក្ខខណ្ឌចំពោះការប្រើប្រាស់ថាមពលរ៉េអាក់ទីវ

ក្នុងការប្រើប្រាស់អគ្គិសនី អ្នកទិញតាមអត្រាថ្លៃលេខរៀងទី១ ដល់អត្រាថ្លៃលេខរៀងទី៤ ត្រូវរក្សាមេគុណអានុភាព (cosφ) នៃការប្រើប្រាស់ឲ្យឋិតនៅក្នុងកម្រិតគុណភាព $\cos\varphi \geq 0.9$ ឬ $tg\varphi \leq 0.484$ មានន័យថា អ្នកទិញទាំងនេះ ត្រូវប្រើប្រាស់ថាមពលរ៉េអាក់ទីវ ពីប្រព័ន្ធផ្គត់ផ្គង់របស់អ្នកលក់ មិនឲ្យលើសពីចំនួនកំណត់មួយដែលកំណត់ដោយ $\cos\varphi \geq 0.9$ ឬ $tg\varphi \leq 0.484$ ។ ក្នុងករណីដែលអ្នកទិញខកខានពុំបានរក្សាមេគុណអានុភាពឲ្យបានដូចការកំណត់ខាងលើ ដោយប្រើថាមពលរ៉េអាក់ទីវ លើសពីចំនួនកំណត់ អ្នកទិញនោះ ត្រូវបង់ថ្លៃបរិមាណថាមពលរ៉េអាក់ទីវ ដែលខ្លួនប្រើលើសពីចំនួនកំណត់ តាមអត្រាថ្លៃថាមពលរ៉េអាក់ទីវ ស្មើនឹង 0.025 ដុល្លារអាមេរិក ក្នុង ១ គីឡូវ៉ុលអំពែររ៉េអាក់ទីវម៉ោង (kVArh) ។ បរិមាណថាមពលរ៉េអាក់ទីវ ដែលប្រើលើសពីការកំណត់ហើយត្រូវទូទាត់ថ្លៃនោះ ត្រូវគណនាតាមរូបមន្ត ៖

$W_{r2} = W_a \times ( (W_{r1} / W_a) - 0.484 )$ ដែល ៖

$W_a$ ៖ បរិមាណថាមពលអាក់ទីវ គិតជា kWh ដែលកត់ត្រាដោយនាឡិកាស្ទង់

$W_{r1}$ ៖ បរិមាណថាមពលរ៉េអាក់ទីវ គិតជា kVArh ដែលកត់ត្រាដោយនាឡិកាស្ទង់

$W_{r2}$ ៖ បរិមាណថាមពលរ៉េអាក់ទីវ គិតជា kVArh ដែលប្រើលើសហើយត្រូវទូទាត់

ក្នុងករណីដែលប្រព័ន្ធប្រើប្រាស់អគ្គិសនីរបស់អ្នកទិញ ត្រូវការប្រើប្រាស់ថាមពលរ៉េអាក់ទីវច្រើនលើសពីការកំណត់ $\cos\phi \geq 0.9$ ឬ $tg\phi \leq 0.484$ អ្នកទិញអាចតម្លើងកុងដង់សាទ័រ ភ្ជាប់ជាមួយបណ្តាញប្រើប្រាស់របស់ខ្លួន ដើម្បីឲ្យកុងដង់សាទ័រនេះ ផលិតថាមពលរ៉េអាក់ទីវ បំពេញបន្ថែមសម្រាប់ការប្រើប្រាស់ផ្ទាល់របស់ខ្លួន ដោយមិនបាច់ប្រើប្រាស់ថាមពលរ៉េអាក់ទីវពីបណ្តាញផ្គត់ផ្គង់របស់អ្នកលក់ ឲ្យលើសពីចំនួនកំណត់ខាងលើឡើយ។ ក្នុងករណីដែលអ្នកទិញប្រើថាមពលរ៉េអាក់ទីវ មិនលើសពីចំនួនកំណត់តាម $\cos\phi \geq 0.9$ ឬ $tg\phi \leq 0.484$ អតិថិជនមិនតម្រូវឲ្យទូទាត់ថ្លៃថាមពលរ៉េអាក់ទីវនេះទេ។

* * * * * * * * * * * *

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អអក

EAC

**អាជ្ញាធរអគ្គិសនីកម្ពុជា**

លេខ ០៣៤ សវ ២០ អអក

# សេចក្តីសម្រេច
# ស្តីពីការកំណត់បញ្ជីថ្លៃលក់អគ្គិសនីសម្រាប់ អ្នកប្រើប្រាស់គ្រប់ប្រភេទដែលទិញអគ្គិសនីពីអនុស្ថានីយ ពីបណ្តាញបញ្ជូនរង និង ពីបណ្តាញចែកចាយមានប្រភពពីបណ្តាញជាតិ របស់អគ្គិសនីកម្ពុជា សម្រាប់ឆ្នាំ២០២០

## អាជ្ញាធរអគ្គិសនីកម្ពុជា

- បានឃើញព្រះរាជក្រម លេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យ លេខ ០៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ស្តីពីគោលការណ៍វាយតម្លៃភាពត្រឹមត្រូវនៃចំណាយក្នុងអាជីវកម្មអគ្គិសនី
- ប្រកាសរបស់ក្រសួងរ៉ែ និងថាមពល លេខ០០៤០ រថ.អវថ.ប្រក ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០ ស្តីពីការដាក់ឲ្យអនុវត្តផែនការបន្ថយថ្លៃលក់អគ្គិសនីឲ្យអ្នកប្រើប្រាស់ និងផែនការកែទម្រង់ការបង់ថ្លៃអគ្គិសនីរបស់អ្នកប្រើប្រាស់សម្រាប់ឆ្នាំ២០២០ និងឆ្នាំ២០២១
- យោងអាជ្ញាបណ្ណ លេខ០០១.ឯអ ដែលបានចេញឲ្យអគ្គិសនីកម្ពុជា នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០២
- យោងការពិគ្រោះយោបល់សាធារណៈពីថ្ងៃទី៣១ ខែមករា ឆ្នាំ២០២០ ដល់ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០២០
- យោងការសម្រេចនៃសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជាលើកទី៣៥៤ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ ២០២០

## សម្រេច

### ប្រការ១

កំណត់បញ្ជីថ្លៃលក់អគ្គិសនីឲ្យ **អគ្គិសនីកម្ពុជា** ដែលបន្ទាប់ពីនេះទៅហៅថា “អ្នកលក់” លក់អគ្គិសនីឲ្យ **អ្នកប្រើប្រាស់អគ្គិសនី** ដែលបន្ទាប់ពីនេះទៅហៅថា “អ្នកទិញ” ដែលភ្ជាប់ចរន្តប្រើប្រាស់អគ្គិសនីពីបណ្តាញចែកចាយរបស់អគ្គិសនីកម្ពុជា ចំនួន ១៧ រាជធានី-ខេត្ត ដែលទទួលប្រភពអគ្គិសនីពីបណ្តាញជាតិ រួមមានរាជធានីភ្នំពេញ តំបន់ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តព្រះសីហនុ ខេត្តតាកែវ ខេត្តកំពត ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តព្រៃវែង ខេត្តកំពង់ចាម នៅលើកោះពីរ ឃុំកោះពីរ ស្រុកក្រូចឆ្មារ និងនៅឃុំជាំក្រវៀន ឃុំជាំ និងផ្នែកខ្លះនៃឃុំចាន់មូល ស្រុកមេមត់ ខេត្តត្បូងឃ្មុំ និងទីរួមខេត្តត្បូងឃ្មុំ ផ្នែកខ្លះនៃស្រុកចិត្របូរី ស្រុកសំបូរ និងក្រុងក្រចេះ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ស្រុកអូររាំង ស្រុកកោះញែក ស្រុកពេជ្រាដា និងក្រុងសែនមនោរម្យ ខេត្តមណ្ឌលគីរី និងតំបន់ក្រៅទីរួមខេត្តរតនគីរី និងផ្នែកខ្លះនៃខេត្តព្រះវិហារ សម្រាប់ឆ្នាំ២០២០ ទៅតាមប្រភេទអ្នកប្រើប្រាស់ លក្ខខណ្ឌភ្ជាប់ និងអត្រាថ្លៃលក់អគ្គិសនី ដូចខាងក្រោម ៖

| ប្រភេទអ្នកប្រើប្រាស់ និងលក្ខខណ្ឌនិញ | ឯកតា | អត្រាថ្លៃលក់ |
|---|---|---|
| **១. អ្នកប្រើប្រាស់ភ្ជាប់ពីខ្សែបណ្ដាញតង់ស្យុងខ្ពស់អនុស្ថានីយ៖** | | |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម | $/kWh | 0.1170 |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 2.90 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកច្រើន (៧ព្រឹកដល់៩យប់) | $/kWh | 0.1150 |
| ៣. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកតិច (៩យប់ដល់៧ព្រឹក) | $/kWh | 0.0940 |
| ➢ ចំពោះអ្នកប្រើប្រាស់មានដាក់តម្លើងប្រភពពន្លឺព្រះអាទិត្យ | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 2.90 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពល (២៤ម៉ោង) | $/kWh | 0.1150 |
| **២. អ្នកប្រើប្រាស់ភ្ជាប់ពីខ្សែបណ្ដាញតង់ស្យុងមធ្យមនៃអនុស្ថានីយ ក្នុងក្រុងភ្នំពេញ និងតាខ្មៅ៖** | | |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម | $/kWh | 0.1320 |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 4.40 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកច្រើន (៧ព្រឹកដល់៩យប់) | $/kWh | 0.1310 |
| ៣. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកតិច (៩យប់ដល់៧ព្រឹក) | $/kWh | 0.0960 |
| ➢ ចំពោះអ្នកប្រើប្រាស់មានដាក់តម្លើងប្រភពពន្លឺព្រះអាទិត្យ | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 4.40 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពល (២៤ម៉ោង) | $/kWh | 0.1310 |
| **៣. អ្នកប្រើប្រាស់ភ្ជាប់ពីខ្សែបណ្ដាញតង់ស្យុងមធ្យមនៃអនុស្ថានីយ ក្រៅក្រុងភ្នំពេញ និងតាខ្មៅ៖** | | |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម | $/kWh | 0.1210 |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 3.20 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកច្រើន (៧ព្រឹកដល់៩យប់) | $/kWh | 0.1190 |
| ៣. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកតិច (៩យប់ដល់៧ព្រឹក) | $/kWh | 0.0960 |
| ➢ ចំពោះអ្នកប្រើប្រាស់មានដាក់តម្លើងប្រភពពន្លឺព្រះអាទិត្យ | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 3.20 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពល (២៤ម៉ោង) | $/kWh | 0.1190 |

| | | |
|---|---|---|
| **៤. អ្នកប្រើប្រាស់ឧស្សាហកម្ម និងកសិកម្មភ្ជាប់ពីខ្សែបណ្ដាញតង់ស្យុងមធ្យម៖** | | |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម | $/kWh | 0.1370 |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 5.00 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកច្រើន (៧ព្រឹកដល់៩យប់) | $/kWh | 0.1300 |
| ៣. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកតិច (៩យប់ដល់៧ព្រឹក) | $/kWh | 0.1100 |
| ➢ ចំពោះអ្នកប្រើប្រាស់មានដាក់តម្លើងប្រភពពន្លឺព្រះអាទិត្យ | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 5.00 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពល (២៤ម៉ោង) | $/kWh | 0.1300 |
| **៥. អ្នកប្រើប្រាស់ប្រភេទពាណិជ្ជកម្ម រដ្ឋបាល និងផ្សេងៗភ្ជាប់ពីខ្សែបណ្ដាញតង់ស្យុងមធ្យម៖** | | |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម | $/kWh | 0.1580 |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 5.80 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកច្រើន (៧ព្រឹកដល់៩យប់) | $/kWh | 0.1500 |
| ៣. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកតិច (៩យប់ដល់៧ព្រឹក) | $/kWh | 0.1240 |
| ➢ ចំពោះអ្នកប្រើប្រាស់មានដាក់តម្លើងប្រភពពន្លឺព្រះអាទិត្យ | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 5.80 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពល (២៤ម៉ោង) | $/kWh | 0.1500 |
| **៦. អ្នកប្រើប្រាស់ឧស្សាហកម្ម និងកសិកម្មភ្ជាប់ពីក្រោមត្រង់ស្វូចែកចាយតាមកុងទ័រ LV (ត្រង់ស្វូផ្ទាល់ខ្លួន)៖** | | |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម | $/kWh | 0.14248 |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 5.00 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកច្រើន (៧ព្រឹកដល់៩យប់) | $/kWh | 0.13520 |
| ៣. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកតិច (៩យប់ដល់៧ព្រឹក) | $/kWh | 0.11440 |
| ➢ ចំពោះអ្នកប្រើប្រាស់មានដាក់តម្លើងប្រភពពន្លឺព្រះអាទិត្យ | | |
| ១. អត្រាថ្លៃប្រើប្រាស់អានុភាព | $/kW/ខែ | 5.00 |
| ២. អត្រាថ្លៃប្រើប្រាស់ថាមពល (២៤ម៉ោង) | $/kWh | 0.1352 |
| **ចំពោះអ្នកសុំឲ្យអ្នកផ្គត់ផ្គង់វិនិយោគត្រង់ស្វូឲ្យខ្លួន៖** | | |
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម | $/kWh | 0.15048 |



**អាជ្ញាធរអគ្គិសនីកម្ពុជា** : ផ្ទះលេខ ០២ ផ្លូវលេខ ២៨២ (ផ្លូវបត់ស្ដាំទី ១ ខាងត្បូងវិមានឯករាជ្យ) សង្កាត់បឹងកេងកង ១ ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទ : ០២៣ ២១៧ ៦៥៤ / ៩៨៧ ៨៩៨ ទូរសារ : ០២៣ ២១៤ ១៤៤, អ៊ីម៉ែល : admin@eac.gov.kh ; Website : www.eac.gov.kh

| | | |
|---|---|---|
| ➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព<br>១. អត្រាថ្លៃប្រើប្រាស់អានុភាព<br>២. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកច្រើន (៧ព្រឹកដល់៩យប់)<br>៣. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកតិច (៩យប់ដល់៧ព្រឹក)<br>➢ ចំពោះអ្នកប្រើប្រាស់មានដាក់តម្លើងប្រភពពន្លឺព្រះអាទិត្យ<br>១. អត្រាថ្លៃប្រើប្រាស់អានុភាព<br>២. អត្រាថ្លៃប្រើប្រាស់ថាមពល (២៤ម៉ោង) | <br>$/kW/ខែ<br>$/kWh<br>$/kWh<br><br>$/kW/ខែ<br>$/kWh | <br>5.00<br>0.14320<br>0.12240<br><br>5.00<br>0.1432 |
| **៧. អ្នកប្រើប្រាស់ប្រភេទពាណិជ្ជកម្ម រដ្ឋបាល និងផ្សេងៗភ្ជាប់ពីក្រោមត្រង់ស្វូចែកចាយតាមកុងទ័រ LV (ត្រង់ស្វូផ្ទាល់ខ្លួន)៖**<br>➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម<br>➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព<br>១. អត្រាថ្លៃប្រើប្រាស់អានុភាព<br>២. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកច្រើន (៧ព្រឹកដល់៩យប់)<br>៣. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកតិច (៩យប់ដល់៧ព្រឹក)<br>➢ ចំពោះអ្នកប្រើប្រាស់មានដាក់តម្លើងប្រភពពន្លឺព្រះអាទិត្យ<br>១. អត្រាថ្លៃប្រើប្រាស់អានុភាព<br>២. អត្រាថ្លៃប្រើប្រាស់ថាមពល (២៤ម៉ោង)<br>**ចំពោះអ្នកសុំឲ្យអ្នកផ្គត់ផ្គង់វិនិយោគត្រង់ស្វូឲ្យខ្លួន៖**<br>➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម<br>➢ ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព<br>១. អត្រាថ្លៃប្រើប្រាស់អានុភាព<br>២. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកច្រើន (៧ព្រឹកដល់៩យប់)<br>៣. អត្រាថ្លៃប្រើប្រាស់ថាមពលក្នុងពេលមានបន្ទុកតិច (៩យប់ដល់៧ព្រឹក)<br>➢ ចំពោះអ្នកប្រើប្រាស់មានដាក់តម្លើងប្រភពពន្លឺព្រះអាទិត្យ<br>១. អត្រាថ្លៃប្រើប្រាស់អានុភាព<br>២. អត្រាថ្លៃប្រើប្រាស់ថាមពល (២៤ម៉ោង) | <br><br>$/kWh<br><br>$/kW/ខែ<br>$/kWh<br>$/kWh<br><br>$/kW/ខែ<br>$/kWh<br><br>$/kWh<br><br>$/kW/ខែ<br>$/kWh<br>$/kWh<br><br>$/kW/ខែ<br>$/kWh | <br><br>0.16432<br><br>5.80<br>0.15600<br>0.12896<br><br>5.80<br>0.1560<br><br>0.17232<br><br>5.80<br>0.16400<br>0.13696<br><br>5.80<br>0.1640 |
| **៨. អ្នកប្រើប្រាស់ភ្ជាប់ពីខ្សែបណ្តាញចែកចាយ LV ៖**<br>៨.១ លំនៅដ្ឋានទិញពីខ្សែបណ្តាញចែកចាយ LV ៖<br>➢ អ្នកប្រើពី ១ ដល់ ១០ គីឡូវ៉ាត់ម៉ោង ក្នុង១ខែ<br>➢ អ្នកប្រើពី ១១ ដល់ ៥០ គីឡូវ៉ាត់ម៉ោង ក្នុង១ខែ | <br><br>៛/kWh<br>៛/kWh | <br><br>380<br>480 |

| | | |
|---|---|---|
| ➢ អ្នកប្រើពី ៥១ ដល់ ២០០ គីឡូវ៉ាត់ម៉ោង ក្នុង១ខែ | ៛/kWh | 610 |
| ➢ អ្នកប្រើលើសពី ២០០ គីឡូវ៉ាត់ម៉ោង ក្នុង១ខែ | ៛/kWh | 730 |
| ៨.២ អ្នកប្រើប្រាស់ប្រភេទផ្សេងទៀត ក្រៅពីលំនៅដ្ឋាន | ៛/kWh | 730 |
| ៨.៣ អ្នកបូមទឹកធ្វើកសិកម្មពេលយប់ពី៩យប់ដល់៧ព្រឹក | ៛/kWh | 480 |
| ៨.៤ សាលារៀន មន្ទីរពេទ្យ មណ្ឌលសុខភាព នៅជនបទ | ៛/kWh | 610 |

**ប្រការ២**

ពិតមែនតែអត្រាថ្លៃអគ្គិសនីដែលកំណត់ក្នុងប្រការ ១ ខាងលើ បានកំណត់ជាប្រាក់ដុល្លារសហរដ្ឋអាមេរិក ប៉ុន្តែ "អ្នកទិញ" ក្នុងអត្រាថ្លៃលេខរៀងទី១ ដល់ទី៧ អាចធ្វើការទូទាត់ថ្លៃអគ្គិសនីជូន "អ្នកលក់" ជាប្រាក់រៀល ដោយគិតតាមអត្រាប្តូរប្រាក់ផ្លូវការដែល "អ្នកលក់" កំណត់លើមូលដ្ឋាននៃអត្រាប្តូរប្រាក់មធ្យមរបស់ធនាគារជាតិនៃកម្ពុជា និងអត្រាប្តូរប្រាក់នៅលើទីផ្សារ ពីថ្ងៃទី២១ ដល់ថ្ងៃចុងខែ មុនថ្ងៃធ្វើវិក្កយបត្រ ។

**ប្រការ៣**

ការអនុវត្តអត្រាថ្លៃលក់អគ្គិសនី តាមប្រភេទអ្នកប្រើប្រាស់ និងលក្ខខណ្ឌ ដែលមានចែងក្នុងប្រការ ១ ខាងលើ ត្រូវគោរពទៅតាមសេចក្តីណែនាំលម្អិត ក្នុងឧបសម្ព័ន្ធដែលភ្ជាប់ជាមួយសេចក្តីសម្រេចនេះ ។

**ប្រការ៤**

បញ្ជីថ្លៃលក់អគ្គិសនីកំណត់ក្នុងប្រការ ១ ខាងលើ អនុវត្តចំពោះតែ "អ្នកទិញ" ដែលមានទីតាំងឋិតនៅក្នុងដែនអាជ្ញាបណ្ណចែកចាយរបស់ "អ្នកលក់" ចំនួន ១៧ រាជធានី-ខេត្ត ដែលទទួលប្រភពអគ្គិសនីពីបណ្តាញជាតិ រួមមានរាជធានីភ្នំពេញ តំបន់ខេត្តកណ្តាល ខេត្តកំពង់ស្ពឺ ខេត្តព្រះសីហនុ ខេត្តតាកែវ ខេត្តកំពត ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តព្រៃវែង ខេត្តកំពង់ចាម នៅលើកោះពីរ ឃុំកោះពីរ ស្រុកក្រូចឆ្មារ និងនៅឃុំជាំក្រវៀន ឃុំជាំ និងផ្នែកខ្លះនៃឃុំចាន់មូល ស្រុកមេមត់ ខេត្តត្បូងឃ្មុំ និងទីរួមខេត្តត្បូងឃ្មុំ ផ្នែកខ្លះនៃស្រុកបិត្របូរី ស្រុកសំបូរ និងក្រុងក្រចេះ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ស្រុកអូររាំង ស្រុកកោះញែក ស្រុកពេជ្រាដា និងក្រុងសែនមនោរម្យ ខេត្តមណ្ឌលគិរី និងតំបន់ក្រៅទីរួមខេត្តរតនគិរី និងផ្នែកខ្លះនៃខេត្តព្រះវិហារ ប៉ុណ្ណោះ ។

**ប្រការ៥**

បញ្ជីថ្លៃលក់អគ្គិសនីថ្មី ក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តចំពោះបរិមាណថាមពលប្រើប្រាស់ចាប់ពីថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០២០ តទៅ រហូតដល់មានការកែសម្រួលឡើងវិញ ដោយអាជ្ញាធរអគ្គិសនីកម្ពុជា ស្របតាមច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។ បញ្ជីថ្លៃលក់អគ្គិសនីពាក់ព័ន្ធ ដែលបានដាក់ឲ្យប្រើប្រាស់មុនសេចក្តីសម្រេចនេះ ត្រូវនិរាករណ៍ ចាប់ពីពេលអនុវត្តបញ្ជីថ្លៃលក់អគ្គិសនីថ្មីនេះ តទៅ ។

**ប្រការ៦**

"អ្នកលក់" និង "អ្នកទិញ" ដូចមានក្នុងប្រការ១ ខាងលើ មានភារកិច្ចអនុវត្តបញ្ជីថ្លៃលក់អគ្គិសនីថ្មីនេះឲ្យមានប្រសិទ្ធភាព ។

**ប្រការ៧**

"អ្នកលក់" មានភារកិច្ចផ្សព្វផ្សាយអំពីខ្លឹមសារនៃសេចក្តីសម្រេចនេះ ដល់អតិថិជនរបស់ខ្លួនគ្រប់ប្រភេទដែលមានការពាក់ព័ន្ធ។

ថ្ងៃអង្គារ ៣កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២០

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**យឹម វិសិដ្ឋ**

<u>ចម្លងជូន</u> ៖

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរ៉ែ និងថាមពល

-សាលារាជធានីភ្នំពេញ

-សាលាខេត្តពាក់ព័ន្ធ

-មន្ទីររ៉ែ និងថាមពល រាជធានីភ្នំពេញ

-មន្ទីររ៉ែ និងថាមពល ខេត្តពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

- អគ្គិសនីកម្ពុជា

"ដើម្បីអនុវត្ត និងផ្សព្វផ្សាយ"

-ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ

## សេចក្តីណែនាំក្នុងការអនុវត្តបញ្ជីថ្លៃលក់អគ្គិសនី សម្រាប់ការលក់អគ្គិសនីឲ្យអ្នកប្រើប្រាស់គ្រប់ប្រភេទដែលទិញអគ្គិសនីពីអនុស្ថានីយ ពីបណ្តាញបញ្ជូនវ និងពីបណ្តាញចែកចាយមានប្រភពពីបណ្តាញជាតិ របស់អគ្គិសនីកម្ពុជា សម្រាប់ឆ្នាំ២០២០

### ១-សេចក្តីណែនាំលម្អិតក្នុងការអនុវត្តបញ្ជីថ្លៃលក់អគ្គិសនីសម្រាប់ការលក់អគ្គិសនីក្នុងអត្រាថ្លៃលេខរៀងទី១ ទី២ ទី៣ ទី៤ ទី៥ ទី៦ និងទី៧

#### ១.១-គោលការណ៍កំណត់អត្រាថ្លៃលក់អគ្គិសនី សម្រាប់ការលក់អគ្គិសនីចេញពីអនុស្ថានីយរបស់បណ្តាញជាតិ ក្នុងអត្រាថ្លៃលេខរៀងទី១ ទី២ និងទី៣

បណ្តាញជាតិ គឺជាការផ្គុំ និងប្រទាក់គ្នានៃបណ្តាញបញ្ជូន និងអនុស្ថានីយតង់ស្យុងខ្ពស់ ដែលមានភារកិច្ចទទួលប្រភពអគ្គិសនីដុំពីស្ថានីយផលិតអគ្គិសនីធំៗក្នុងស្រុក និងពីប្រភពអគ្គិសនីនាំចូលពីប្រទេសជិតខាង រួចធ្វើការបញ្ជូនប្រភពអគ្គិសនីទាំងនេះ ទៅកាន់ខេត្តនានា ដើម្បីប្រគល់ទៅឲ្យអនុស្ថានីយនៅតាមបណ្តាខេត្ត ។ ប្រភពអគ្គិសនីនេះ ក្រៅពីបញ្ចេញផ្គត់ផ្គង់ឲ្យតំបន់ចែកចាយទីរួមខេត្ត ក៏ត្រូវបញ្ជូនបន្តទៀត ទៅកាន់តំបន់ជនបទនានាក្នុងខេត្តដោយបណ្តាញបញ្ជូនវ ។ បណ្តាញជាតិ គឺជាសសៃឈាមមេដែលសំខាន់បំផុតក្នុងការផ្គត់ផ្គង់អគ្គិសនី ការរអាក់រអួលណាមួយផ្នែកបច្ចេកទេស ឬផ្នែកហិរញ្ញវត្ថុលើបណ្តាញជាតិនេះសុទ្ធតែធ្វើឲ្យប៉ះពាល់ធំដុំលើការផ្គត់ផ្គង់អគ្គិសនីទូទាំងប្រទេស និងធ្វើឲ្យមានការខាតបង់ធំដែលចាំបាច់ត្រូវតែចៀសវាង។ ម្យ៉ាងទៀត ការអភិវឌ្ឍន៍បណ្តាញជាតិឲ្យទាន់តាមផែនការ គឺជាមូលដ្ឋានចាំបាច់បំផុតសម្រាប់សម្រេចគោលដៅនៃការអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មរបស់រាជរដ្ឋាភិបាល។ ដូច្នេះ គោលការណ៍កំណត់អត្រាថ្លៃលក់អគ្គិសនីពីអនុស្ថានីយបណ្តាញជាតិ គឺត្រូវកំណត់យ៉ាងណាឲ្យចំណូលដែលទទួលបានតាមអត្រាថ្លៃលក់នេះ អាចរក្សានូវស្ថេរភាពនៃអាជីវកម្មរបស់បណ្តាញជាតិ អាចធ្វើការដំណើរការបណ្តាញជាតិប្រកបដោយសុក្រិតភាព និងអាចមានសល់ទុនសម្រាប់ចូលរួមអភិវឌ្ឍន៍បណ្តាញជាតិឲ្យទាន់តាមផែនការកំណត់។

#### ១.២-លក្ខខណ្ឌសំខាន់ៗសម្រាប់កំណត់ប្រភេទអ្នកប្រើប្រាស់ធុនធំ សម្រាប់ការភ្ជាប់ចរន្ត និងការលក់អគ្គិសនីចេញពីអនុស្ថានីយ ក្នុងអត្រាថ្លៃលេខរៀងទី១ ទី២ និងទី៣

##### ក-លក្ខខណ្ឌទូទៅ

ការភ្ជាប់ចរន្ត និងការលក់អគ្គិសនីចេញពីអនុស្ថានីយរបស់បណ្តាញជាតិបញ្ជូនអគ្គិសនី ត្រូវមានកិច្ចព្រមព្រៀងទិញ-លក់អគ្គិសនី ដែលកំណត់នូវលក្ខខណ្ឌពាក់ព័ន្ធជាមួយការភ្ជាប់ចរន្ត ការដំណើរការការប្រើប្រាស់ ការកត់ត្រាបរិមាណប្រើប្រាស់ ការទូទាត់ ព្រមទាំងអាណត្តិនៃការទិញលក់។ កិច្ចព្រមព្រៀងនេះត្រូវគោរពទៅតាមបទប្បញ្ញត្តិ កូដ នីតិវិធី និងសេចក្តីណែនាំនានារបស់អាជ្ញាធរអគ្គិសនីកម្ពុជា។ ចំពោះតំបន់ចែកចាយនីមួយៗរបស់អគ្គិសនីកម្ពុជាផ្ទាល់ ដែលបានភ្ជាប់ជាមួយអនុស្ថានីយរបស់បណ្តាញ

ជាតិបញ្ជូនអគ្គិសនី ហើយបានយកប្រភពអគ្គិសនីពីអនុស្ថានីយ ថ្លៃនៃប្រភពអគ្គិសនីដែលតំបន់ចែកចាយនីមួយៗបានយកពីប្រព័ន្ធបណ្តាញជាតិបញ្ជូនអគ្គិសនីនោះ ក៏ត្រូវគិតតាមលក្ខខណ្ឌភ្ជាប់ និងអត្រាថ្លៃដែលបានកំណត់ក្នុងបញ្ជីថ្លៃលក់នេះដែរ។

### ខ-លក្ខខណ្ឌសម្រាប់ការភ្ជាប់ចរន្តពីទ្វារចរន្តតង់ស្យុងខ្ពស់អនុស្ថានីយក្នុងអត្រាថ្លៃលេខរៀងទី១

នៅពេលដែលអនុស្ថានីយត្រូវបានដាក់ឲ្យដំណើរការរួច អ្នកប្រើប្រាស់អគ្គិសនីដែលមានលក្ខខណ្ឌសមស្រប ត្រូវបានអនុញ្ញាតឲ្យភ្ជាប់ចរន្តទិញអគ្គិសនីពីទ្វារចរន្តតង់ស្យុងខ្ពស់របស់អនុស្ថានីយ ។ ការអនុញ្ញាតឲ្យភ្ជាប់ចរន្តពីទ្វារចរន្តតង់ស្យុងខ្ពស់របស់អនុស្ថានីយនេះ មិនត្រូវមានការរើសអើងទេ ឲ្យតែអ្នកទិញនោះមានអានុភាពលើសពី ១០ មេហ្គាវ៉ាត់ និងមានការសិក្សាលើការប្រើប្រាស់ប្រចាំខែត្រឹមត្រូវ ដែលបង្ហាញអំពីបរិមាណប្រើប្រាស់ថាមពលប្រចាំខែសមស្របដែលអគ្គិសនីកម្ពុជាអាចទទួលយកបាន ។ ការភ្ជាប់ចរន្ត និងការទិញអគ្គិសនីពីទ្វារចរន្តតង់ស្យុងខ្ពស់របស់អនុស្ថានីយបណ្តាញជាតិ ត្រូវឈរលើមូលដ្ឋាននៃកិច្ចព្រមព្រៀងទិញ-លក់អគ្គិសនី រវាងអគ្គិសនីកម្ពុជា និងអ្នកទិញ ដែលបានកំណត់នៅក្នុងចំណុច "ក" ខាងលើ។

### គ-លក្ខខណ្ឌសម្រាប់ការភ្ជាប់ចរន្តពីទ្វារចរន្តតង់ស្យុងមធ្យមអនុស្ថានីយក្នុងអត្រា ថ្លៃលេខរៀងទី២ និងទី៣

អនុស្ថានីយទាំងឡាយ ដែលមានគោលដៅផ្តល់ប្រភពអគ្គិសនីឲ្យអ្នកទិញដែលជាអ្នកប្រើប្រាស់តែងមានត្រង់ស្វូបញ្ចុះតង់ស្យុងពីតង់ស្យុងខ្ពស់មកតង់ស្យុងមធ្យម និងមានទ្វារចរន្តតង់ស្យុងមធ្យមមួយចំនួនសម្រាប់ផ្តល់ប្រភពអគ្គិសនីតាមតង់ស្យុងមធ្យមឲ្យអ្នកទិញ ។ បរិក្ខាទ្វារចរន្តតង់ស្យុងមធ្យមនៅអនុស្ថានីយបណ្តាញជាតិទាំងអស់ គឺជាកម្មសិទ្ធរបស់អ្នកលក់ និងឋិតនៅក្នុងបញ្ជីអចលនទ្រព្យរបស់អ្នកលក់ដែលពុំអាចទាមទារដោយអ្នកទិញជាអ្នកវិនិយោគបានឡើយ ។ ការអនុញ្ញាតឲ្យអ្នកទិញភ្ជាប់ចរន្តផ្ទាល់ពីទ្វារចរន្តតង់ស្យុងមធ្យមនៃអនុស្ថានីយ ត្រូវធ្វើជាទូទៅដោយមិនមានការរើសអើង ឲ្យតែអនុស្ថានីយនោះមានអានុភាពសល់ និងមានទ្វារចរន្តនៅទំនេរ និងឲ្យតែអ្នកទិញនោះគោរពទៅតាមលក្ខខណ្ឌដូចខាងក្រោម ៖

លក្ខខណ្ឌភ្ជាប់ ៖ អនុញ្ញាតចំពោះតែអ្នកប្រើប្រាស់អគ្គិសនីតង់ស្យុងមធ្យមធំៗដែលត្រូវការអានុភាពមិនតូចជាង១០មេហ្គាវ៉ាត់ និងដែលមានខ្សែបណ្តាញតង់ស្យុងមធ្យមភ្ជាប់ពីទីតាំងរបស់ខ្លួនមកទ្វារចរន្តនេះ មានប្រវែងមិនលើសពី១០គីឡូម៉ែត្រ (តាមប្រកាសរបស់អតីតក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ស្តីពី "ការកំណត់គោលការណ៍ និងលក្ខខណ្ឌ សម្រាប់ការចេញអាជ្ញាបណ្ណបញ្ជូនសម្រាប់គោលបំណងពិសេសនៅព្រះរាជាណាចក្រកម្ពុជា") ។ ខ្សែបណ្តាញតង់ស្យុងមធ្យមដែលមានប្រវែងមិនលើសពី១០គីឡូម៉ែត្រដែលជាកម្មសិទ្ធ និងដំណើរការដោយអ្នកទិញអគ្គិសនីដុំ ឬអ្នកទិញអគ្គិសនីធំ ឬអ្នកទិញអគ្គិសនីតង់ស្យុងមធ្យម ហើយប្រើប្រាស់សម្រាប់តែ

ដឹកនាំថាមពលអគ្គិសនី ទៅឲ្យកន្លែងប្រើប្រាស់ផ្ទាល់ខ្លួននោះ ត្រូវបានចាត់ទុកជាផ្នែកមួយនៃបរិក្ខាអគ្គិសនីរបស់អ្នកទិញ ដោយមិនចាំបាច់មានអាជ្ញាបណ្ណសម្រាប់ដំណើរការខ្សែបណ្តាញនោះទេ។ អ្នកទិញអគ្គិសនីធំ និងអ្នកទិញអគ្គិសនីតង់ស្យុងមធ្យម ដែលមានទីតាំងលើសពី១០គីឡូម៉ែត្រពីអនុស្ថានីយ ត្រូវតែភ្ជាប់ចរន្តប្រើប្រាស់ពីអ្នកធ្វើសេវាកម្មបញ្ជូនរង ឬអ្នកចែកចាយបន្ត ។ ប្រសិនបើមានការចាំបាច់ត្រូវភ្ជាប់ចរន្តប្រើប្រាស់ពីទ្វារចេញអនុស្ថានីយដោយខានពុំបាន អ្នកទិញនោះ ត្រូវស្នើសុំអាជ្ញាបណ្ណ ដើម្បីដំណើរការខ្សែបណ្តាញបញ្ជូនរងក្នុងគោលបំណងពិសេស ដែលលើស១០គីឡូម៉ែត្រនោះជាមុនសិន មុនអនុញ្ញាតឲ្យភ្ជាប់ចរន្តពីទ្វារចេញអនុស្ថានីយបាន។ ក្នុង ទ្វារចេញ១ អ្នកលក់អាចកំណត់ឲ្យអ្នកទិញអាចភ្ជាប់លើសពី១បាន ឲ្យតែការផ្គត់ផ្គង់អានុភាព និងប្រព័ន្ធការពាររបស់ការភ្ជាប់នេះគោរពតាមគោលការណ៍បច្ចេកទេស។ អ្នកទិញអាចយកចរន្តនេះទៅកាន់ទីតាំងរបស់ខ្លួន ហើយបង្កើតជាប្រព័ន្ធចែកចាយផ្ទៃក្នុងដោយឡែកក្នុងទីតាំងប្រើប្រាស់របស់ខ្លួន។

**លក្ខខណ្ឌប្រើប្រាស់ ៖** អានុភាពចុះកិច្ចសន្យាចាប់ពី១០មេហ្គាវ៉ាត់ឡើង ការប្រើប្រាស់ធម្មតានៃអានុភាពចុះកិច្ចសន្យាដែលមានទំហំធំ ដូច្នេះ ជាធម្មតាប្រហែល៥០% រីឯថ្ងៃប្រើប្រាស់គឺថ្ងៃធ្វើការងារ២៥ថ្ងៃ(មិនគិតថ្ងៃអាទិត្យ) និងការប្រើប្រាស់មធ្យម១០ម៉ោងក្នុង១ថ្ងៃ។ ដូច្នេះ ក្នុង១ខែការប្រើប្រាស់ថាមពលអាក់ទីវមធ្យមគិតជាគីឡូវ៉ាត់ម៉ោង = ទំហំស្នើសុំគិតជាគីឡូវ៉ាត់ x ៥០% x ១០ម៉ោង x ២៥ថ្ងៃ។ ថាមពលអាក់ទីវដែលកំណត់ឲ្យអ្នកទិញជានាទិញអប្បបរមា សម្រាប់ការស្នើសុំអានុភាពខាងលើគឺកំណត់ត្រឹម២០% នៃការប្រើប្រាស់មធ្យមខាងលើ ។ ការកំណត់បរិមាណថាមពលដែលត្រូវជានាទិញអប្បបរមានេះ គឺដើម្បីឲ្យអ្នកទិញជានាទិញតាមចំនួនមួយ ដែលរក្សាតុល្យភាពនៃការចំណាយរបស់អ្នកលក់ក្នុងការបម្រុងទុកអានុភាពសម្រាប់ផ្គត់ផ្គង់ឲ្យទៅអ្នកទិញតាមទំហំស្នើសុំប្រើប្រាស់របស់អ្នកទិញ។

## ១.៣-លក្ខខណ្ឌសំខាន់ៗ សម្រាប់កំណត់ប្រភេទអ្នកប្រើប្រាស់ធុនធំ និងធុនមធ្យម ប្រភេទឧស្សាហកម្ម និងកសិកម្ម" និង"ប្រភេទពាណិជ្ជកម្ម រដ្ឋបាល និងផ្សេងៗ" ក្នុងអត្រាថ្លៃលេខរៀងទី៤ ទី៥ ទី៦ និងទី៧

លក្ខខណ្ឌសំខាន់ៗ សម្រាប់កំណត់ប្រភេទនៃអ្នកប្រើប្រាស់ធុនធំ និងធុនមធ្យម ប្រភេទឧស្សាហ-កម្ម និងកសិកម្ម" និង "ប្រភេទពាណិជ្ជកម្ម រដ្ឋបាល និងផ្សេងៗ" មានដូចខាងក្រោម ៖

*អតិថិជនធុនមធ្យម ទិញពីនាឡិកាស្ទង់តង់ស្យុងទាប ដាក់ក្រោមត្រង់ស្វូចែកចាយរបស់អគ្គិសនីកម្ពុជា និង ដាក់ក្រោមត្រង់ស្វូចែកចាយដែលខ្លួនបានវិនិយោគ*

*លក្ខខណ្ឌភ្ជាប់បណ្តាញ ៖* អតិថិជនធុនមធ្យមដែលទិញអគ្គិសនីពីនាឡិកាស្ទង់តង់ស្យុងទាបដាក់ក្រោមត្រង់ស្វូចែកចាយរបស់អគ្គិសនីកម្ពុជា គឺជាអតិថិជន ដែលភ្ជាប់ចរន្តពីបន្ទប់

ត្រង់ស្វូផ្ទាល់ ដោយដាក់នាឡិកាស្ទង់ នៅក្រោមទ្វារចរន្តតង់ស្យុងទាបនៃត្រង់ស្វូចែកចាយក្នុងបន្ទប់ចែកចាយ ឬនៃត្រង់ស្វូចែកចាយលើបង្គោល ដែលវិនិយោគសាងសង់ដោយអគ្គិសនីកម្ពុជា ។ អតិថិជនធុនមធ្យមដែលទិញអគ្គិសនីពីនាឡិកាស្ទង់តង់ស្យុងទាប ដាក់ក្រោមត្រង់ស្វូចែកចាយដែលខ្លួនវិនិយោគ គឺជាអតិថិជនដែលភ្ជាប់ចរន្តពីបន្ទប់ត្រង់ស្វូផ្ទាល់ ដោយដាក់នាឡិកាស្ទង់នៅក្រោមទ្វារចរន្តតង់ស្យុងទាប នៃត្រង់ស្វូចែកចាយក្នុងបន្ទប់ចែកចាយ ឬនៃត្រង់ស្វូចែកចាយលើបង្គោល ដែលវិនិយោគសាងសង់ដោយខ្លួនឯងផ្ទាល់ ។ ចំពោះអតិថិជនធុនមធ្យមទាំងពីរប្រភេទនេះអានុភាពចុះកិច្ចសន្យាផ្គត់ផ្គង់អគ្គិសនីចាប់ពី ១០០ kVA ដល់ ២៧៥ kVA (កាវ៉េអា)។

*លក្ខខណ្ឌប្រើប្រាស់ ៖* មិនមានការកំណត់លក្ខខណ្ឌប្រើប្រាស់អប្បបរមាឡើយ។

***អតិថិជនធុនធំ ដែលទិញអគ្គិសនីពីនាឡិកាស្ទង់ ដែលដាក់នៅផ្នែកតង់ស្យុងមធ្យម***

*លក្ខខណ្ឌភ្ជាប់បណ្តាញ ៖* អតិថិជនធុនធំដែលទិញពីនាឡិកាស្ទង់ ដែលដាក់នៅផ្នែកតង់ស្យុងមធ្យម គឺជាអតិថិជន ដែលភ្ជាប់ចរន្តផ្ទាល់ពីបណ្តាញតង់ស្យុងមធ្យមរបស់អគ្គិសនីកម្ពុជា ។ អតិថិជនអាចមានបន្ទប់ត្រង់ស្វូ ឬត្រង់ស្វូលើបង្គោលភ្ជាប់លើបណ្តាញតង់ស្យុងមធ្យមរបស់អគ្គិសនីកម្ពុជា ដោយដាក់នាឡិកាស្ទង់នៅផ្នែកតង់ស្យុងមធ្យម ។ អតិថិជនក៏អាចភ្ជាប់ចរន្តពីបណ្តាញតង់ស្យុងមធ្យម ហើយយកចរន្តតង់ស្យុងមធ្យមនេះ ទៅកាន់ទីតាំងរបស់ខ្លួន ដោយបង្កើតជាប្រព័ន្ធចែកចាយដោយឡែករបស់ខ្លួន ដែលមានត្រង់ស្វូចែកចាយច្រើននៅក្នុងទីតាំងប្រើប្រាស់របស់ខ្លួនបានដែរ ។

*លក្ខខណ្ឌប្រើប្រាស់ ៖* មិនមានការកំណត់លក្ខខណ្ឌប្រើប្រាស់អប្បបរមាឡើយ។

## ២-សេចក្តីណែនាំសម្រាប់ការទូទាត់ថ្លៃប្រើប្រាស់អគ្គិសនី សម្រាប់អ្នកទិញ ក្នុងអត្រាថ្លៃលេខរៀងទី១ ទី២ ទី៣ ទី៤ ទី៥ ទី៦ និងទី៧

ក្នុងការកំណត់ថ្លៃលក់អគ្គិសនី សម្រាប់អ្នកទិញ ក្នុងអត្រាថ្លៃលេខរៀងទី១ ទី២ ទី៣ ទី៤ ទី៥ ទី៦ និងទី៧ ដូចមានក្នុងប្រការ១ នៃសេចក្តីសម្រេចខាងលើ ត្រូវបានកំណត់ជាប្រាក់ដុល្លារអាមេរិក ហើយអ្នកទិញអាចទូទាត់ជាប្រាក់រៀល ដោយគិតតាមអត្រាប្តូរប្រាក់ផ្លូវការ ដែលអ្នកលក់កំណត់លើមូលដ្ឋាននៃអត្រាប្តូរប្រាក់មធ្យមរបស់ធនាគារជាតិនៃកម្ពុជា និងអត្រាប្តូរប្រាក់ផ្លូវការលើទីផ្សារពីថ្ងៃទី២១ ដល់ថ្ងៃចុងខែ មុនថ្ងៃធ្វើវិក្កយបត្រ ។ ក្នុងករណីនេះ ហានិភ័យនៃអត្រាប្តូរប្រាក់ ប្រសិនបើមានការប្រែប្រួល គឺអ្នកទិញ ជាអ្នកទទួលបន្ទុក ។

### ៣-សេចក្តីណែនាំសម្រាប់អនុវត្តអត្រាថ្លៃលក់អគ្គិសនី សម្រាប់អ្នកទិញ ក្នុងអត្រាថ្លៃលេខរៀងទី១ ទី២ ទី៣ ទី៤ ទី៥ ទី៦ និងទី៧ ដែលមានតម្លើងប្រព័ន្ធពន្លឺព្រះអាទិត្យភ្ជាប់សាំងក្រូនជាមួយប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីរបស់អ្នកលក់

សម្រាប់អ្នកទិញដែលឋិតក្នុងអត្រាថ្លៃលេខរៀងទី១ ទី២ ទី៣ ទី៤ ទី៥ ទី៦ និងទី៧ ដែលមានតម្លើងប្រព័ន្ធពន្លឺព្រះអាទិត្យភ្ជាប់សាំងក្រូនជាមួយប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី" ទាំងអតិថិជនចាស់ និងទាំងអតិថិជនថ្មី គឺពុំមានជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម និងជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាពទេ គឺត្រូវអនុវត្ត "បញ្ជីថ្លៃលក់អគ្គិសនីសម្រាប់អ្នកប្រើប្រាស់មានដាក់តម្លើងប្រកពពន្លឺព្រះអាទិត្យ" ដែលមានកំណត់ក្នុងប្រការ ១ ខាងលើ ។

ចំពោះអ្នកទិញធុនធំ ភ្ជាប់លើតង់ស្យុងខ្ពស់ (HV) និងធុនធំ ភ្ជាប់លើតង់ស្យុងមធ្យម (MV) ទាំងអស់ ដែលមានតម្លើងប្រព័ន្ធពន្លឺព្រះអាទិត្យភ្ជាប់សាំងក្រូនជាមួយប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីបណ្តាញជាតិ និងមានការអនុញ្ញាតពីអ្នកលក់នោះ "បញ្ជីថ្លៃលក់អគ្គិសនីសម្រាប់អ្នកប្រើប្រាស់មានដាក់តម្លើងប្រកពពន្លឺព្រះអាទិត្យ" ដែលមានកំណត់ក្នុងប្រការ ១ ខាងលើ នឹងត្រូវជំនួសសេចក្តីសម្រេចចាស់របស់អាជ្ញាធរអគ្គិសនីកម្ពុជា លេខ ៣៩៥.សរ.១៨.អអក ចុះថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០១៨ ស្តីពីការកំណត់បញ្ជីថ្លៃលក់អគ្គិសនីសម្រាប់អ្នកផ្គត់ផ្គង់អគ្គិសនីលក់ឲ្យអ្នកប្រើប្រាស់ធុនធំ និងធុនធំ ដែលមានតម្លើងប្រព័ន្ធពន្លឺព្រះអាទិត្យ ភ្ជាប់សាំងក្រូនជាមួយប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីរបស់បណ្តាញជាតិ សម្រាប់ការប្រើប្រាស់អគ្គិសនីផ្ទាល់ខ្លួន ។

### ៤-សេចក្តីណែនាំសម្រាប់អនុវត្តអត្រាថ្លៃលក់អគ្គិសនី សម្រាប់អ្នកទិញ ក្នុងអត្រាថ្លៃលេខរៀងទី១ ទី២ ទី៣ ទី៤ ទី៥ ទី៦ និងទី៧ ដែលពុំមានតម្លើងប្រព័ន្ធពន្លឺព្រះអាទិត្យភ្ជាប់សាំងក្រូនជាមួយប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីរបស់អ្នកលក់

សម្រាប់អ្នកទិញដែលមានអត្រាថ្លៃក្នុងលេខរៀងទី១ ទី២ ទី៣ ទី៤ ទី៥ ទី៦ និងទី៧ ដែលមិនមានតម្លើងប្រព័ន្ធពន្លឺព្រះអាទិត្យ ត្រូវបានផ្តល់ជម្រើស ចំនួន២ គឺ ១.ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម ឬ ២.ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព ។

#### ៤.១-លក្ខខណ្ឌសម្រាប់អនុវត្តជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម

សម្រាប់អ្នកទិញដែលមានអត្រាថ្លៃក្នុងលេខរៀងទី១ ទី២ ទី៣ ទី៤ ទី៥ ទី៦ និងទី៧ ដែលមិនមានតម្លើងប្រព័ន្ធពន្លឺព្រះអាទិត្យ ជ្រើសរើសយកបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម គឺត្រូវអនុវត្តតាមអត្រាថ្លៃលក់ដែលមានកំណត់ក្នុងប្រការ ១ ខាងលើ និងលក្ខខណ្ឌនៃការភ្ជាប់ ដែលមានកំណត់ក្នុងសេចក្តីណែនាំលម្អិតនេះ ។ អ្នកទិញក្នុងប្រភេទនេះគឺបង់ថ្លៃប្រើប្រាស់អគ្គិសនីរបស់ខ្លួន ទៅតាមបរិមាណអគ្គិសនីប្រចាំខែគិតជាគីឡូវ៉ាត់ម៉ោង គុណនឹងអត្រាថ្លៃលក់ថាមពល ប៉ុណ្ណោះ ដែលមានកំណត់ក្នុងប្រកាស ១ ខាងលើ ។ ប្រសិនបើអ្នកទិញចង់ប្តូរពី "ការបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម" ទៅជ្រើសរើស "ការបង់ថ្លៃលក់អគ្គិសនីតាមពេលវេលា និងអានុភាព" វិញ អ្នកទិញ ត្រូវស្នើសុំទៅអ្នកលក់អំពីការជ្រើសរើស "ការបង់ថ្លៃលក់

អគ្គិសនីតាមពេលវេលា និងអានុភាព" ហើយអ្នកលក់ត្រូវពិនិត្យរៀបចំឲ្យអ្នកទិញអនុវត្តជម្រើស"ការបង់ថ្លៃលក់អគ្គិសនីតាមពេលវេលា និងអានុភាព" តាមការស្នើសុំរបស់អ្នកទិញ។

**៤.២-លក្ខខណ្ឌសំខាន់ៗសម្រាប់អនុវត្តជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព**

១.អត្រាថ្លៃអានុភាព (Capacity Charge) គិតជាដុល្លារអាមេរិក ក្នុង១គីឡូវ៉ាត់ ក្នុង១ខែ ផ្អែកលើទំហំអានុភាពនៃកិច្ចសន្យា គិតជាគីឡូវ៉ាត់ (kW) ។ ទំហំអានុភាពនៃកិច្ចសន្យា គឺជាអានុភាពដែលស្នើសុំដោយអ្នកទិញ និងទទួលការយល់ព្រមពីអ្នកលក់ ដោយមានបញ្ជាក់ក្នុងកិច្ចព្រមព្រៀងទិញ-លក់អគ្គិសនី ។ ទំហំអានុភាពនៃកិច្ចសន្យា អាចខុសពីទំហំអានុភាពតម្លើងសរុបរបស់ត្រង់ស្វូ ។ ក្នុងដំណាក់កាលដំបូង អ្នកទិញអាចស្នើសុំកែសម្រួលទំហំអានុភាពនៃកិច្ចសន្យា (Contracted Capacity) បាន ហើយអ្នកលក់ត្រូវពិនិត្យលើសំណើសុំរបស់អ្នកទិញ ដើម្បីកំណត់ទំហំអានុភាពនៃកិច្ចសន្យា (Contracted Capacity)ថ្មី ដោយផ្អែកលើស្ថានភាពជាក់ស្តែង ។ ក្នុងរយៈពេល ១ (មួយ) ឆ្នាំ បន្ទាប់ពីបានកំណត់ទំហំអានុភាពនៃកិច្ចសន្យា អ្នកទិញពុំអាចបន្ថយទំហំអានុភាពនៃកិច្ចសន្យា (Contracted Capacity) បានទេ ។ ក្នុងករណីអ្នកទិញចង់តម្លើងទំហំអានុភាពនៃកិច្ចសន្យា (Contracted Capacity) អ្នកទិញត្រូវដាក់ពាក្យស្នើសុំជាលាយលក្សណ៍អក្សរទៅអ្នកលក់ ហើយអ្នកលក់ត្រូវពិនិត្យសំណើសុំ និងត្រូវឆ្លើយតបទៅអ្នកទិញ តើខ្លួនមានអានុភាពអាច ផ្តល់ឲ្យអ្នកទិញបាន ឬពុំបាន ។

២.អត្រាថ្លៃថាមពល (Energy Charge) គិតជាដុល្លារអាមេរិក ក្នុង១គីឡូវ៉ាត់ម៉ោង ផ្អែកលើបរិមាណថាមពល ដែលប្រើប្រាស់តាមពេលវេលា គឺ ១.ក្នុងពេលមានបន្ទុកច្រើន ពីម៉ោង 07:00 ព្រឹក ដល់ម៉ោង 21:00 យប់ និង២.ក្នុងពេលមានបន្ទុកតិច ពីម៉ោង 21:00 យប់ ដល់ម៉ោង 07:00 ព្រឹក ។

៣.ចំពោះអ្នកទិញ ដែលកំពុងអនុវត្តបញ្ជីថ្លៃអគ្គិសនីតាមពេលវេលា តាមសេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជាលេខ ០៤៧.សរ.១៧.អអក ចុះថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៧ ត្រូវបានផ្តល់ជម្រើសបង់ថ្លៃអគ្គិសនីថ្មី ចំនួន ២ គឺ ១."ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម" ឬ ២."ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព" ។ បន្ទាប់ពី អាជ្ញាធរអគ្គិសនីកម្ពុជាចេញសេចក្តីសម្រេចថ្មីខាងលើនេះ អ្នកលក់ត្រូវចេញវិក្កយបត្រថ្លៃអគ្គិសនីឲ្យអ្នកទិញខាងលើតាម "ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព" ស្របតាមសេចក្តីសម្រេចថ្មីនេះ ជាបណ្តោះអាសន្នសិន ដោយភ្ជាប់ជាមួយច្បាប់ចម្លងសេចក្តីសម្រេចស្តីពីបញ្ជីថ្លៃលក់ថ្មីនេះ ។ ប្រសិនបើ អ្នកទិញមានបំណងចង់ផ្លាស់ប្តូរមកប្រើប្រាស់ "ជម្រើសបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម" វិញ អ្នកទិញត្រូវស្នើសុំទៅអ្នកលក់តាមលិខិតជាលាយលក្សណ៍អក្សរ ក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃចេញវិក្កយបត្រថ្លៃអគ្គិសនីថ្មី ។ បន្ទាប់ពីទទួលលិខិតស្នើសុំពីអ្នកទិញ អ្នកលក់ត្រូវកែតម្រូវវិក្កយបត្រថ្លៃអគ្គិសនីដែលចេញរួចហើយនោះ ពី "ការបង់ថ្លៃអគ្គិសនីតាម

ពេលវេលា និងអានុភាព" ទៅ "ការបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម" វិញ និងបន្តអនុវត្តអត្រាថ្លៃមធ្យមសម្រាប់ការចេញវិក្កយបត្រថ្លៃអគ្គិសនីឲ្យអ្នកទិញនៅខែបន្ទាប់ តទៅ ។ ក្នុងករណីអ្នកទិញពុំបានស្នើសុំទៅអ្នកលក់តាមលិខិតជាលាយលក្សណ៍អក្សរ ក្នុងរយៈពេលកំណត់ខាងលើទេ ចាត់ទុកថា អ្នកទិញជ្រើសរើស "ការបង់ថ្លៃលក់អគ្គិសនីតាមពេលវេលា និងអានុភាព" ។ ទន្ទឹមនឹងនេះ ចំពោះអ្នកទិញជ្រើសរើស "ការបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព" រួចហើយ អ្នកទិញនោះពុំអាចប្ដូរមកជ្រើសរើស "ការបង់ថ្លៃអគ្គិសនីតាមអត្រាថ្លៃមធ្យម" វិញបានទេ ។

៤.ចំពោះអ្នកទិញដែលអនុវត្ត "ជម្រើសបង់ថ្លៃអគ្គិសនីតាមពេលវេលា និងអានុភាព" នាឡិកាស្ទង់នឹងកត់ត្រាតម្រូវការការប្រើប្រាស់ខ្ពស់បំផុតរៀងរាល់ ១៥ នាទីម្ដង ក្នុងខួបស្រង់ថាមពល ។ ប្រសិនបើការកត់ត្រានោះបង្ហាញថា តម្រូវការការប្រើប្រាស់ខ្ពស់បំផុត ខ្ពស់ជាងទំហំអានុភាពនៃកិច្ចសន្យានោះ អ្នកទិញត្រូវបង់ការពិន័យអត្រាថ្លៃអានុភាព (Capacity Charge) ស្មើនឹង ២ ដង នៃអត្រាថ្លៃអានុភាពធម្មតា ចំពោះអានុភាពដែលលើស សម្រាប់ខួបស្រង់ថាមពលនោះ ។

## ៥-លក្ខខណ្ឌចំពោះការប្រើប្រាស់ថាមពលរ៉េអាក់ទីវ

ក្នុងការប្រើប្រាស់អគ្គិសនី អ្នកទិញតាមអត្រាថ្លៃលេខរៀងទី១ ដល់អត្រាថ្លៃលេខរៀងទី៧ ត្រូវរក្សាមេគុណអានុភាព ($\cos\varphi$) នៃការប្រើប្រាស់ឲ្យឋិតនៅក្នុងកម្រិតគុណភាព $\cos\varphi \geq 0.9$ ឬ $tg\varphi \leq 0.484$ មានន័យថា អ្នកទិញទាំងនេះ ត្រូវប្រើប្រាស់ថាមពលរ៉េអាក់ទីវ ពីប្រព័ន្ធផ្គត់ផ្គង់របស់អ្នកលក់ មិនឲ្យលើសពីចំនួនកំណត់មួយដែលកំណត់ដោយ $\cos\varphi \geq 0.9$ ឬ $tg\varphi \leq 0.484$ ។ ក្នុងករណីដែលអ្នកទិញខកខានពុំបានរក្សាមេគុណអានុភាពឲ្យបានដូចការកំណត់ខាងលើ ដោយប្រើថាមពលរ៉េអាក់ទីវ លើសពីចំនួនកំណត់ អ្នកទិញនោះ ត្រូវបង់ថ្លៃបរិមាណថាមពលរ៉េអាក់ទីវ ដែលខ្លួនប្រើលើសពីចំនួនកំណត់ តាមអត្រាថ្លៃថាមពលរ៉េអាក់ទីវ ស្មើនឹង 0.025 ដុល្លារអាមេរិក ក្នុង ១ គីឡូវ៉ុលអំពែររ៉េអាក់ទីវម៉ោង (kVArh) ។ បរិមាណថាមពលរ៉េអាក់ទីវ ដែលប្រើលើសពីការកំណត់ហើយត្រូវទូទាត់ថ្លៃនោះ ត្រូវគណនាតាមរូបមន្ត ៖

$W_{r2} = W_a \times ( (W_{r1} / W_a) - 0.484 )$ ដែល ៖

$W_a$ ៖ បរិមាណថាមពលអាក់ទីវ គិតជា kWh ដែលកត់ត្រាដោយនាឡិកាស្ទង់

$W_{r1}$ ៖ បរិមាណថាមពលរ៉េអាក់ទីវ គិតជា kVArh ដែលកត់ត្រាដោយនាឡិកាស្ទង់

$W_{r2}$ ៖ បរិមាណថាមពលរ៉េអាក់ទីវ គិតជា kVArh ដែលប្រើលើសហើយត្រូវទូទាត់

ក្នុងករណីដែលប្រព័ន្ធប្រើប្រាស់អគ្គិសនីរបស់អ្នកទិញ ត្រូវការប្រើប្រាស់ថាមពលរ៉េអាក់ទីវច្រើនលើសពីការកំណត់ $\cos\phi \geq 0.9$ ឬ $tg\phi \leq 0.484$ អ្នកទិញអាចតម្លើងកុងដង់សាទ័រ ភ្ជាប់ជាមួយបណ្ដាញប្រើប្រាស់របស់ខ្លួន ដើម្បីឲ្យកុងដង់សាទ័រនេះ ផលិតថាមពលរ៉េអាក់ទីវ បំពេញបន្ថែមសម្រាប់ការប្រើប្រាស់ផ្ទាល់របស់ខ្លួន ដោយមិនបាច់ប្រើប្រាស់ថាមពលរ៉េអាក់ទីវពីបណ្ដាញផ្គត់ផ្គង់របស់អ្នកលក់ ឲ្យលើសពីចំនួនកំណត់ខាងលើឡើយ។ ក្នុងករណីដែលអ្នកទិញប្រើថាមពលរ៉េអាក់ទីវ មិនលើសពីចំនួនកំណត់តាម $\cos\phi \geq 0.9$ ឬ $tg\phi \leq 0.484$ អតិថិជនមិនតម្រូវឲ្យទូទាត់ថ្លៃថាមពលរ៉េអាក់ទីវនេះទេ។

## ៦-សេចក្តីណែនាំសម្រាប់អនុវត្តអត្រាថ្លៃលក់អគ្គិសនី ចំពោះអ្នកប្រើប្រាស់ភ្ជាប់ពីខ្សែបណ្តាញចែកចាយ LV ក្នុងលេខរៀងទី៨

### ៦.១-ការអនុវត្តអត្រាថ្លៃលក់អគ្គិសនីចំពោះលំនៅដ្ឋានពីខ្សែបណ្តាញចែកចាយ LV ក្នុងតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា ចំនួន ១៧ រាជធានី-ខេត្ត

អត្រាថ្លៃលក់អគ្គិសនី សម្រាប់អតិថិជនលំនៅដ្ឋានពលរដ្ឋកម្ពុជា នៅក្នុងតំបន់ចែកចាយរបស់អគ្គិសនីកម្ពុជា ចំនួន ១៧ រាជធានី-ខេត្ត សម្រាប់ឆ្នាំ ២០២០ មាន ៤ ប្រភេទ គឺ ៣៨០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង, ៤៨០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង, ៦១០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង និង ៧៣០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ។ អត្រាថ្លៃ ៣៨០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង, អត្រាថ្លៃ ៤៨០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង និង អត្រាថ្លៃ ៦១០ រៀល ក្នុង ១ គីឡូវ៉ាតម៉ោង គឺជាអត្រាអនុគ្រោះដែលរាជរដ្ឋាភិបាល បានសម្រេចជាគោលនយោបាយ តម្រូវឲ្យអគ្គិសនីកម្ពុជាឧបត្ថម្ភធនចំពោះលំនៅដ្ឋានធុនតូច និងធុនមធ្យម ។ លំនៅដ្ឋានធុនតូច ដែលប្រើប្រាស់អគ្គិសនីមិនលើសពី ១០ គីឡូវ៉ាត់ម៉ោង ក្នុង ១ ខែ ត្រូវបានរាជរដ្ឋាភិបាល តម្រូវឲ្យអគ្គិសនីកម្ពុជាអនុគ្រោះឲ្យបង់ថ្លៃអគ្គិសនីត្រឹម ៣៨០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង, លំនៅដ្ឋានធុនតូចដែលប្រើប្រាស់អគ្គិសនីក្នុងចន្លោះពី ១១ ដល់ ៥០ គីឡូវ៉ាត់ម៉ោង ក្នុង ១ ខែ ក៏ត្រូវបានរាជរដ្ឋាភិបាលតម្រូវឲ្យអគ្គិសនីកម្ពុជាអនុគ្រោះឲ្យបង់ថ្លៃអគ្គិសនីត្រឹម ៤៨០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ចំណែកឯលំនៅដ្ឋានធុនមធ្យម ដែលប្រើប្រាស់អគ្គិសនីក្នុងចន្លោះពី ៥១ ដល់ ២០០ គីឡូវ៉ាត់ម៉ោង ក្នុង ១ ខែ ក៏ត្រូវបានរាជរដ្ឋាភិបាលតម្រូវឲ្យអគ្គិសនីកម្ពុជាអនុគ្រោះឲ្យបង់ថ្លៃអគ្គិសនីត្រឹម ៦១០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ។ ចំពោះលំនៅដ្ឋានធុនធំ ដែលប្រើអគ្គិសនីចាប់ពី ២០១ គីឡូវ៉ាត់ម៉ោង ក្នុង ១ ខែ ឡើងទៅ ត្រូវទូទាត់ការប្រើប្រាស់អគ្គិសនីតាមអត្រាថ្លៃ គឺ ៧៣០រៀល ក្នុង១គីឡូវ៉ាត់ម៉ោង ។ ដោយសារក្រុមអតិថិជន ប្រភេទនេះ គឺជាប្រជាពលរដ្ឋកម្ពុជា ដូច្នេះ អត្រាថ្លៃលក់អគ្គិសនីកំណត់ជារៀល ដោយមិនគិតពីហានិភ័យនៃអត្រាប្តូរប្រាក់ ប្រសិនបើមានការប្រែប្រួលនៅក្នុងរយៈពេលនៃការអនុវត្តបញ្ជីថ្លៃលក់អគ្គិសនីនេះ ។

នីតិវិធីក្នុងការកំណត់អត្រាថ្លៃលក់អគ្គិសនីណាដែលត្រូវអនុវត្តសម្រាប់លំនៅដ្ឋានមួយៗ ក្នុងខែនីមួយៗ គឺការពិនិត្យចំនួនគីឡូវ៉ាត់ម៉ោងដែលលំនៅដ្ឋាននោះបានប្រើប្រាស់នៅក្នុងខែនីមួយៗ ។ ប្រសិនបើនៅក្នុងខែដែលត្រូវគិតថ្លៃអគ្គិសនី ចំនួនប្រើប្រាស់សរុបរបស់លំនៅដ្ឋានណាមួយ មិនលើសពី១០ គីឡូវ៉ាត់ម៉ោង នៅក្នុងខែនោះ អត្រាថ្លៃលក់អគ្គិសនីសម្រាប់លំនៅដ្ឋាននោះ គឺ ៣៨០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង, ប្រសិនបើនៅក្នុងខែដែលត្រូវគិតថ្លៃអគ្គិសនី ចំនួនប្រើប្រាស់សរុបរបស់លំនៅដ្ឋានណាមួយ ប្រើប្រាស់ចាប់ពី ១១ គីឡូវ៉ាត់ម៉ោង ប៉ុន្តែមិនលើសពី ៥០ គីឡូវ៉ាត់ម៉ោង នៅក្នុងខែនោះ អត្រាថ្លៃលក់អគ្គិសនីសម្រាប់លំនៅដ្ឋាននោះ គឺ ៤៨០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង និងចំនួនប្រើប្រាស់សរុបរបស់លំនៅដ្ឋានណាមួយប្រើប្រាស់ពី ៥១ គីឡូវ៉ាត់ម៉ោង ប៉ុន្តែមិនលើសពី ២០០ គីឡូវ៉ាត់ម៉ោង នៅក្នុងខែនោះ អត្រាថ្លៃលក់អគ្គិសនីសម្រាប់លំនៅដ្ឋាននោះ គឺ ៦១០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ប៉ុន្តែប្រសិនបើនៅក្នុងខែដែលត្រូវគិតថ្លៃអគ្គិសនី ចំនួនប្រើប្រាស់សរុបរបស់លំនៅដ្ឋានណាមួយ ប្រើប្រាស់ចាប់ពី ២០១ គីឡូវ៉ាត់ម៉ោងឡើង នៅក្នុងខែនោះ អត្រាថ្លៃលក់អគ្គិសនីសម្រាប់លំនៅដ្ឋាននោះ គឺ ៧៣០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ។

ដើម្បីរក្សាសមធម៌ រវាងអគ្គិសនីកម្ពុជា និងអតិថិជនលំនៅដ្ឋានក្នុងការកំណត់អត្រាថ្លៃលក់សម្រាប់លំនៅដ្ឋាននីមួយៗ អាជ្ញាធរអគ្គិសនីកម្ពុជា កំណត់ឲ្យអគ្គិសនីកម្ពុជាធ្វើការកត់ត្រាបរិមាណថាមពលអគ្គិសនីដែលអតិថិជនលំនៅដ្ឋាន បានប្រើប្រាស់ប្រចាំខែ ដូចខាងក្រោម ៖

១- បរិមាណថាមពលអគ្គិសនីដែលយកមកគិតថ្លៃលក់ ត្រូវជាបរិមាណថាមពលដែលបានកត់ត្រាពីនាឡិកាស្ទង់របស់អតិថិជននីមួយៗជាក់ស្តែង ។

២- ថ្ងៃកំណត់ចុះពិនិត្យ និងកត់ត្រាតួលេខនាឡិកាស្ទង់របស់អតិថិជនលំនៅដ្ឋាន ត្រូវថេរសម្រាប់ក្រុមអតិថិជននីមួយៗ ធ្វើយ៉ាងណាឲ្យរយៈពេលកត់ត្រាបរិមាណថាមពលប្រើប្រាស់របស់អតិថិជនលំនៅដ្ឋាននីមួយៗ មានរយៈពេលស្មើនឹងមួយខែ ។

៣- យោងតាមស្ថានភាពពិសេស ឬការលំបាកជាក់ស្តែងក្នុងការងារកត់ត្រា ក្នុងកាលៈទេសៈណាមួយ អាចអនុញ្ញាតឲ្យរយៈពេលកត់ត្រាថាមពលជាក់ស្តែង លើស ឬខ្វះ ១ ថ្ងៃ មានន័យថា នៅក្នុងចន្លោះ ១ ថ្ងៃ មុន ឬ ១ ថ្ងៃ ក្រោយ ។

### ៦.២-សេចក្តីណែនាំសម្រាប់អនុវត្តអត្រាថ្លៃលក់អគ្គិសនី សម្រាប់អ្នកប្រើប្រាស់ប្រភេទផ្សេងៗ ក្រៅពីលំនៅដ្ឋាន

អត្រាថ្លៃលក់អគ្គិសនីសម្រាប់អ្នកប្រើប្រាស់ប្រភេទផ្សេងៗ ក្រៅពីលំនៅដ្ឋានដែលទិញពីខ្សែបណ្តាញចែកចាយសាធារណៈតាមតង់ស្យុងទាប គឺ ៧៣០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង ។ ថ្លៃលក់អគ្គិសនីកំណត់ឲ្យលក់ជារៀល ដោយមិនគិតពីហានិភ័យនៃអត្រាប្តូរប្រាក់ ប្រសិនបើមានការប្រែប្រួល ។ អ្នកប្រើប្រាស់ប្រភេទផ្សេងៗ ក្រៅពីលំនៅដ្ឋាន ដែលប្រើប្រាស់អត្រាថ្លៃ ៧៣០ រៀល ក្នុង ១ គីឡូវ៉ាត់ម៉ោង នេះរួមមានសហគ្រាស និងអង្គភាពរដ្ឋ ឬចម្រុះរដ្ឋ សិប្បកម្ម និងហាងលក់ទំនិញដែលភ្ជាប់ពីខ្សែសាធារណៈ។

លក្ខខណ្ឌសំខាន់ៗ សម្រាប់កំណត់ចំពោះអ្នកប្រើប្រាស់ប្រភេទផ្សេងៗ ក្រៅពីលំនៅដ្ឋាន មានដូចខាងក្រោម ៖

**អតិថិជនធុនតូច ទិញពីនាឡិកាស្ទង់តង់ស្យុងទាប ភ្ជាប់ពីបណ្តាញចែកចាយតង់ស្យុងទាប**

**លក្ខខណ្ឌភ្ជាប់បណ្តាញ ៖** ភ្ជាប់ពីខ្សែបណ្តាញចែកចាយសាធារណៈតង់ស្យុងទាប ដែលតម្លើងតាមដងផ្លូវសាធារណៈ។ អានុភាពអតិបរិមា ដែលអនុញ្ញាតឲ្យអ្នកទិញភ្ជាប់លើខ្សែបណ្តាញចែកចាយតង់ស្យុងទាបសាធារណៈ ត្រូវបានកំណត់ដោយលិខិតបទដ្ឋានរបស់អ្នកលក់ផ្ទាល់ ឲ្យតែអ្នកទិញដែលបានភ្ជាប់ចរន្តពីខ្សែបណ្តាញចែកចាយសាធារណៈតង់ស្យុងទាបនេះ ត្រូវបានចាត់ទុកថាជាអ្នកទិញធុនតូចដែលទិញពីនាឡិកាស្ទង់តង់ស្យុងទាប ភ្ជាប់ពីបណ្តាញចែកចាយតង់ស្យុងទាបទាំងអស់ ។

**លក្ខខណ្ឌប្រើប្រាស់** ៖ មិនមានការកំណត់លក្ខខណ្ឌប្រើប្រាស់អប្បបរមាឡើយ។

## ៦.៣-សេចក្តីណែនាំសម្រាប់អនុវត្តអត្រាថ្លៃលក់អគ្គិសនី សម្រាប់អ្នកបូមទឹកធ្វើកសិកម្មពេលយប់

គឺជាអ្នកប្រើប្រាស់ដែលមានលក្ខណៈជាសហគមន៍កសិករ ដែលត្រូវការអគ្គិសនីសម្រាប់យកទៅបូមទឹកធ្វើកសិកម្ម ។ អ្នកប្រើប្រាស់ប្រភេទនេះត្រូវបានរាជរដ្ឋាភិបាលតម្រូវឲ្យអគ្គិសនីកម្ពុជា ផ្តល់នូវភាពអនុគ្រោះពិសេស ឲ្យបង់ថ្លៃអគ្គិសនីត្រឹម ៤៨០ រៀល ក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់បូមទឹកធ្វើកសិកម្មនៅពេលយប់ ដែលត្រូវអនុវត្តគោលការណ៍ ដូចខាងក្រោម៖

ក. សម្រាប់អ្នកប្រើប្រាស់បូមទឹកសម្រាប់ធ្វើកសិកម្មពេលយប់ពីម៉ោង ៩យប់ ដល់ម៉ោង ៧ព្រឹក

ខ. អ្នកប្រើប្រាស់ត្រូវធ្វើការស្នើសុំទៅមូលនិធិអគ្គិសនីជនបទ ដើម្បីពិនិត្យលទ្ធភាពក្នុងការតភ្ជាប់ខ្សែបណ្តាញអគ្គិសនី សម្រាប់បូមទឹកធ្វើកសិកម្មនៅពេលយប់

គ. ការតភ្ជាប់ខ្សែបណ្តាញ LV សម្រាប់បូមទឹកធ្វើកសិកម្ម ត្រូវរៀបចំដោយមូលនិធិអគ្គិសនីជនបទ

ឃ. មូលនិធិអគ្គិសនីជនបទ ត្រូវតម្លើងនាឡិកាស្ទង់អេឡិចត្រូនិច ដែលមានកំណត់ម៉ោងប្រើប្រាស់នៅពេលយប់ពីម៉ោង ៩យប់ ដល់ម៉ោង ៧ព្រឹក សម្រាប់ប្រើប្រាស់រួមមួយដាច់ដោយឡែក ដើម្បីកត់ត្រាថាមពលប្រើប្រាស់រួមសម្រាប់គិតលុយពីអ្នកកាន់អាជ្ញាបណ្ណ

ង. អ្នកប្រើប្រាស់នីមួយៗ ដែលជាសហគមន៍កសិករ ត្រូវតម្លើងនាឡិកាស្ទង់របស់ខ្លួនមួយដាច់ដោយឡែកផ្សេងទៀត ដោយតភ្ជាប់ចេញពីនាឡិកាស្ទង់មេរបស់មូលនិធិអគ្គិសនីជនបទ សម្រាប់កត់ត្រាថាមពលប្រើប្រាស់រៀងៗ ដើម្បីគិតលុយថ្លៃអគ្គិសនីឲ្យអ្នកកាន់អាជ្ញាបណ្ណ ។

## ៦.៤-សេចក្តីណែនាំសម្រាប់អនុវត្តអត្រាថ្លៃលក់អគ្គិសនី សម្រាប់សាលារៀន មន្ទីរពេទ្យ មណ្ឌលសុខភាព នៅជនបទ

គឺជាអ្នកប្រើប្រាស់ ដែលរាជរដ្ឋាភិបាលតម្រូវឲ្យអគ្គិសនីកម្ពុជាផ្តល់នូវភាពអនុគ្រោះពិសេស ឲ្យបង់ថ្លៃស្មើ ៦១០ រៀល ក្នុង១គីឡូវ៉ាត់ម៉ោង ដែលមាន២ប្រភេទដូចខាងក្រោម៖

ក. អ្នកប្រើប្រាស់ដែលទិញអគ្គិសនីយកទៅប្រើប្រាស់ក្នុងសាលារៀន មន្ទីរពេទ្យ មណ្ឌលសុខភាព វិទ្យាស្ថាន មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយប្រើប្រាស់ថវិការដ្ឋនៅតាមបណ្តាឃុំ-ស្រុក ។

ខ. អ្នកប្រើប្រាស់ដែលទិញអគ្គិសនីទៅប្រើប្រាស់ក្នុងសាលារៀនឯកជន សកលវិទ្យាល័យឯកជន មហាវិទ្យាល័យឯកជន សមាគមន៍បើកបង្រៀនមិនយកកម្រៃសេវា មជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ មន្ទីរពេទ្យឯកជន មន្ទីរសម្រាកព្យាបាលជម្ងឺ និងសម្ភពឯកជន មិនយកកម្រៃសេវាពីសាធារណៈជន មានទីតាំងនៅតំបន់ជនបទ តាមបណ្តាឃុំ-ស្រុក ។

* * * * * * * * * * * *

អ អ ក

EAC

**អាជ្ញាធរអគ្គិសនីកម្ពុជា**

លេខ០៣០ ៧៩៤៤០ អអក

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# សេចក្តីសម្រេច

## ស្តីពីការកំណត់បញ្ជីថ្លៃលក់អគ្គិសនីសម្រាប់អ្នកកាន់អាជ្ញាបណ្ណ ដែលទិញអគ្គិសនីពីអនុស្ថានីយ និងពីបណ្តាញបញ្ជូនរង ដែលមានប្រភព ពីបណ្តាញជាតិរបស់អគ្គិសនីកម្ពុជា សម្រាប់ឆ្នាំ ២០២០

## អាជ្ញាធរអគ្គិសនីកម្ពុជា

- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០១/០៣ ចុះថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ០៥៤.អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៥ ស្តីពីគោលការណ៍វាយតម្លៃភាពត្រឹមត្រូវនៃចំណាយក្នុងអាជីវកម្មអគ្គិសនី
- ប្រកាសរបស់ក្រសួងរ៉ែ និងថាមពល លេខ០០៤០ រ៉ថ.អវថ.ប្រក ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០២០ ស្តីពីការដាក់ឲ្យអនុវត្តផែនការបន្ថយថ្លៃលក់អគ្គិសនីឲ្យអ្នកប្រើប្រាស់ និងផែនការកែទម្រង់ការបង់ថ្លៃអគ្គិសនីរបស់អ្នកប្រើប្រាស់សម្រាប់ឆ្នាំ២០២០ និងឆ្នាំ២០២១
- យោងអាជ្ញាបណ្ណលេខ០០១.ឯអ ដែលបានចេញឲ្យអគ្គិសនីកម្ពុជា នៅថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០០២
- យោងការគណនាថ្លៃអគ្គិសនីត្រូវលក់ចេញពីទ្វារចន្លនៃអនុស្ថានីយ និងពីបណ្តាញបញ្ជូនរងដែលប្រភពចេញពីបណ្តាញជាតិរបស់អគ្គិសនីកម្ពុជា
- យោងការផ្សព្វផ្សាយជាសាធារណៈ លើគម្រោងកំណត់បញ្ជីថ្លៃលក់អគ្គិសនីសម្រាប់អ្នកកាន់អាជ្ញាបណ្ណ ដែលទិញអគ្គិសនីពីអនុស្ថានីយ និងពីបណ្តាញបញ្ជូនរង ដែលមានប្រភពពីបណ្តាញជាតិរបស់អគ្គិសនីកម្ពុជា និងអ្នកកាន់អាជ្ញាបណ្ណបញ្ជូនរងឯកជន សម្រាប់ខួបឆ្នាំ២០២០ ចាប់ពីថ្ងៃទី១៥ ខែមករា រហូតដល់ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០
- យោងការសម្រេចនៃសម័យប្រជុំរបស់អាជ្ញាធរអគ្គិសនីកម្ពុជាលើកទី៣៥៣ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ ។

### សម្រេច

**ប្រការ ១**

កំណត់បញ្ជីថ្លៃលក់អគ្គិសនីរបស់ **អគ្គិសនីកម្ពុជា** ដែលបន្ទាប់ពីនេះទៅហៅថា "អ្នកលក់" សម្រាប់ការលក់អគ្គិសនីឲ្យ **អ្នកកាន់អាជ្ញាបណ្ណ** ដែលបន្ទាប់ពីនេះទៅហៅថា "អ្នកទិញ" ចេញពីទ្វារចន្លនៃអនុស្ថានីយរបស់ប្រព័ន្ធបណ្តាញជាតិបញ្ជូនអគ្គិសនី និងពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា ដែលយកប្រភពអគ្គិសនីពីបណ្តាញជាតិ តាមប្រភេទនៃការទិញ និងអត្រាថ្លៃលក់អគ្គិសនី មានដូចខាងក្រោម ៖

| ប្រភេទអ្នកកាន់អាជ្ញាបណ្ណ និងលក្ខខណ្ឌនៃការទិញ | អត្រាថ្លៃលក់ |
|---|---|
| ទិញអគ្គិសនីពីទ្វារចេន្ត MV នៃអនុស្ថានីយ | 0.1138 $US/kWh |
| ទិញអគ្គិសនីពីខ្សែបញ្ជូនរង តាមនាឡិកាស្ទង់ MV | 0.1290 $US/kWh |
| ទិញអគ្គិសនីពីខ្សែបញ្ជូនរង ក្រោមត្រង់ស្វូនិយោគដោយ «អ្នកទិញ» តាមនាឡិកាស្ទង់ LV | 0.13416 $US/kWh |
| ទិញអគ្គិសនីពីខ្សែបញ្ជូនរង ក្រោមត្រង់ស្វូនិយោគដោយ «អ្នកលក់» តាមនាឡិកាស្ទង់ LV | 0.14216 $US/kWh |

## ប្រការ ២

ពិតមែនតែអត្រាថ្លៃអគ្គិសនីដែលកំណត់ក្នុងប្រការ ១ ខាងលើ បានកំណត់ជាប្រាក់ដុល្លារសហរដ្ឋអាមេរិក ប៉ុន្តែ "អ្នកទិញ" អាចធ្វើការទូទាត់ថ្លៃអគ្គិសនីជូន "អ្នកលក់" ជាប្រាក់រៀល ដោយគិតតាមអត្រាប្តូរប្រាក់ផ្លូវការដែលអ្នកលក់កំណត់លើមូលដ្ឋាន នៃអត្រាប្តូរប្រាក់មធ្យមរបស់ធនាគារជាតិនៃកម្ពុជា និងគិតតាមអត្រាប្តូរប្រាក់ទីផ្សារនៅថ្ងៃទូទាត់ ពីថ្ងៃទី២១ ដល់ថ្ងៃចុងខែ មុនថ្ងៃធ្វើវិក្កយបត្រ។

## ប្រការ ៣

ក្នុងការទិញអគ្គិសនីតាមតង់ស្យុងមធ្យមពី "អ្នកលក់" តាមការកំណត់ក្នុងប្រការ ១ ខាងលើ "អ្នកទិញ" ត្រូវរក្សាមេគុណអានុភាព ($\cos\varphi$) នៃការទទួលអគ្គិសនីរបស់ខ្លួនឲ្យឋិតនៅក្នុងកម្រិតគុណភាព $\cos\varphi \geq 0.9$ ឬ $tg\varphi \leq 0.484$ មានន័យថា "អ្នកទិញ" មានសិទ្ធិប្រើប្រាស់ថាមពលរ៉េអាក់ទីវចេញពីប្រព័ន្ធផ្គត់ផ្គង់របស់ "អ្នកលក់" មិនលើសពីចំនួនកំណត់មួយដែលកំណត់ដោយ $\cos\varphi \geq 0.9$ ឬ $tg\varphi \leq 0.484$ ។ ក្នុងករណីដែលអ្នកទិញខកខានពុំបានរក្សាមេគុណអានុភាពឲ្យបានដូចការកំណត់ខាងលើ ដោយប្រើប្រាស់ថាមពលរ៉េអាក់ទីវពីប្រព័ន្ធរបស់ "អ្នកលក់" លើសពីចំនួនកំណត់ "អ្នកទិញ" នោះត្រូវបង់ថ្លៃបរិមាណថាមពលរ៉េអាក់ទីវដែលខ្លួនប្រើប្រាស់លើសនេះ តាមអត្រាថ្លៃថាមពលរ៉េអាក់ទីវស្មើនឹង 0.025$US ក្នុង១គីឡូវ៉ុលអំពែររ៉េអាក់ទីវម៉ោង (kVArh) ។

## ប្រការ ៤

ការលក់ និងការទិញអគ្គិសនី តាមបញ្ជីថ្លៃលក់ដែលកំណត់ក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្តតាមសេចក្តីពន្យល់ និងសេចក្តីណែនាំលម្អិតក្នុងឧបសម្ព័ន្ធដែលភ្ជាប់ជាមួយ ។

## ប្រការ ៥

"អ្នកលក់" និង "អ្នកទិញ" ដែលពាក់ព័ន្ធជាមួយបញ្ជីថ្លៃលក់ថ្មីខាងលើ មានភារកិច្ចអនុវត្តបញ្ជីថ្លៃលក់អគ្គិសនីនេះ ឲ្យមានប្រសិទ្ធភាព ។

## ប្រការ ៦

អត្រាថ្លៃថ្មីដែលបានកំណត់ខាងលើនេះ ត្រូវអនុវត្តចំពោះបរិមាណអគ្គិសនីដែលបានទិញចាប់ពីចុងខែមករា ឆ្នាំ២០២០ ដែលត្រូវនឹងការចេញវិក្កយបត្រចាប់ពីចុងខែកុម្ភៈ ឆ្នាំ២០២០ តទៅ។ ក្នុងករណីខ្លឹមសារនៃកិច្ចព្រមព្រៀងរវាង"អ្នកលក់" និង"អ្នកទិញ" បានចែងនូវអត្រាថ្លៃខុសពីការកំណត់ក្នុងប្រការខាងលើ "អ្នកលក់" និង "អ្នកទិញ" ត្រូវធ្វើការកែសម្រួលអត្រាថ្លៃលក់អគ្គិសនីនៅក្នុងកិច្ចព្រមព្រៀងទិញលក់នោះឡើងវិញជាបន្ទាន់ ដើម្បីអនុវត្តអត្រាថ្លៃលក់អគ្គិសនីឲ្យស្របតាមការកំណត់នៅក្នុងសេចក្តីសម្រេចនេះ។

ការកែសម្រួលកិច្ចព្រមព្រៀងទិញលក់ឡើងវិញនេះ ប្រសិនបើមាន ត្រូវតែធ្វើយ៉ាងណាឲ្យអត្រាថ្លៃថ្មី អាចអនុវត្តចំពោះបរិមាណអគ្គិសនីដែលបានទិញចាប់ពីចុងខែមករា ឆ្នាំ២០២០ តទៅ។

**ប្រការ ៧**

ក្នុងករណីពិសេស "អ្នកលក់" អាចស្នើសុំមកអាជ្ញាធរអគ្គិសនីកម្ពុជា ធ្វើការសម្រេចដោយឡែកនូវអត្រាថ្លៃខុសពីអត្រាថ្លៃកំណត់ជាទូទៅនៅក្នុងប្រការ ១ ខាងលើ ដើម្បីប៉ះប៉ូវផ្ដល់លទ្ធភាពឲ្យ "អ្នកទិញ"ណាមួយ អាចលក់អគ្គិសនីជុំឲ្យតំបន់ចែកចាយរបស់គេ តាមអត្រាថ្លៃដូចបានកំណត់ក្នុងប្រការ ១ ខាងលើ ។

**ប្រការ ៨**

លើកលែងតែការកំណត់ពេលវេលាដែលចែងក្នុងប្រការ ៦ ខាងលើ ខ្លឹមសារនៃសេចក្ដីសម្រេចនេះ ត្រូវចូលជាធរមាន ដើម្បីអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។ បញ្ជីថ្លៃលក់នេះ អាចធ្វើការកែសម្រួលឡើងវិញដោយអាជ្ញាធរអគ្គិសនីកម្ពុជា ស្របតាមការកំណត់របស់ច្បាប់ស្ដីពីអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា ។ រាល់សេចក្ដីសម្រេចស្ដីពីបញ្ជីថ្លៃលក់អគ្គិសនីចេញមុនទាំងឡាយ ដែលផ្ទុយពីខ្លឹមសារនៃសេចក្ដីសម្រេចនេះ ត្រូវនិរាករណ៍ ចាប់ពីពេលអនុវត្តបញ្ជីថ្លៃលក់អគ្គិសនីថ្មីនេះ។

**ប្រការ ៩**

"អ្នកលក់" មានភារកិច្ចផ្សព្វផ្សាយអំពីខ្លឹមសារនៃសេចក្ដីសម្រេចនេះ ដល់អតិថិជនរបស់ខ្លួនគ្រប់ប្រភេទដែលមានការពាក់ព័ន្ធ ។

ថ្ងៃសុក្រ ៦រោច ខែមាឃ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០

**អាជ្ញាធរអគ្គិសនីកម្ពុជា**

**ប្រធាន**

**យឹម វិសិដ្ឋ**

ចម្លងជូន ៖

-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

-ក្រសួងរ៉ែ និងថាមពល

-សាលារាជធានី-ខេត្ត ដែលពាក់ព័ន្ធ

-មន្ទីររ៉ែ និងថាមពល រាជធានី/ខេត្ត ដែលពាក់ព័ន្ធ

"ដើម្បីជូនជ្រាប"

-អគ្គិសនីកម្ពុជា

"ដើម្បីអនុវត្ត និងផ្សព្វផ្សាយ"

-ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ

## សេចក្តីណែនាំលម្អិតក្នុងការអនុវត្តបញ្ជីថ្លៃលក់អគ្គិសនីសម្រាប់អ្នកកាន់អាជ្ញាបណ្ណ ដែលទិញអគ្គិសនីពីអនុស្ថានីយ និងពីបណ្តាញបញ្ជូនរង ដែលមានប្រភពពី បណ្តាញជាតិរបស់អគ្គិសនីកម្ពុជា សម្រាប់ឆ្នាំ ២០២០

### ១-សេចក្តីណែនាំលម្អិតក្នុងការអនុវត្តបញ្ជីថ្លៃលក់អគ្គិសនីសម្រាប់ការលក់អគ្គិសនីចេញពីអនុស្ថានីយ

#### ១.១-គោលការណ៍កំណត់អត្រាថ្លៃលក់អគ្គិសនី សម្រាប់ការលក់អគ្គិសនីចេញពីអនុស្ថានីយរបស់បណ្តាញជាតិ

បណ្តាញជាតិ គឺជាការផ្គុំ និងប្រទាក់គ្នានៃបណ្តាញបញ្ជូន និងអនុស្ថានីយតង់ស្យុងខ្ពស់ ដែលមានភារកិច្ចទទួលប្រភពអគ្គិសនីជុំពីស្ថានីយផលិតអគ្គិសនីធំៗក្នុងស្រុក និងពីប្រភពអគ្គិសនីនាំចូលពីប្រទេសជិតខាង រួចធ្វើការបញ្ជូនប្រភពអគ្គិសនីទាំងនេះ ទៅកាន់ខេត្តនានា ដើម្បីប្រគល់ទៅឲ្យអនុស្ថានីយនៅតាមបណ្តាខេត្ត ។ ប្រភពអគ្គិសនីនេះ ក្រៅពីបញ្ចេញផ្គត់ផ្គង់ឲ្យតំបន់ចែកចាយទីរួមខេត្ត ក៏ត្រូវបញ្ជូនបន្តទៀត ទៅកាន់តំបន់ជនបទនានាក្នុងខេត្តដោយបណ្តាញបញ្ជូនរង ។ បណ្តាញជាតិ គឺជាសរសៃឈាមមេដែលសំខាន់បំផុតក្នុងការផ្គត់ផ្គង់អគ្គិសនី ការរអាក់រអួលណាមួយផ្នែកបច្ចេកទេសឬផ្នែកហិរញ្ញវត្ថុលើបណ្តាញជាតិនេះសុទ្ធតែធ្វើឲ្យប៉ះពាល់ធំដុំលើការផ្គត់ផ្គង់អគ្គិសនីទូទាំងប្រទេស និងធ្វើឲ្យមានការខាតបង់ធំដែលចាំបាច់ត្រូវតែចៀសវាង។ ម្យ៉ាងទៀត ការអភិវឌ្ឍន៍បណ្តាញជាតិឲ្យទាន់តាមផែនការគឺជាមូលដ្ឋានចាំបាច់បំផុតសម្រាប់សម្រេចគោលដៅនៃការអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មរបស់រាជរដ្ឋាភិបាល។ ដូច្នេះ គោលការណ៍កំណត់អត្រាថ្លៃលក់អគ្គិសនីពីអនុស្ថានីយបណ្តាញជាតិ គឺត្រូវកំណត់យ៉ាងណាឲ្យចំណូលដែលទទួលបានតាមអត្រាថ្លៃលក់នេះ អាចរក្សានូវស្ថេរភាពនៃអាជីវកម្មរបស់បណ្តាញជាតិ អាចធ្វើការដំណើរការបណ្តាញជាតិប្រកបដោយសុក្រិតភាព និងអាចមានសល់ទុនសម្រាប់ចូលរួមអភិវឌ្ឍន៍បណ្តាញជាតិឲ្យទាន់តាមផែនការកំណត់។

#### ១.២-សេចក្តីណែនាំអនុវត្តបញ្ជីថ្លៃលក់អគ្គិសនីសម្រាប់ការភ្ជាប់ចរន្ត និងការលក់អគ្គិសនីចេញពីអនុស្ថានីយ

#### ក-លក្ខខណ្ឌទូទៅ

ការភ្ជាប់ចរន្តនិងការលក់អគ្គិសនីចេញពីអនុស្ថានីយរបស់បណ្តាញជាតិបញ្ជូនអគ្គិសនី ត្រូវមានកិច្ចព្រមព្រៀងទិញលក់អគ្គិសនី ដែលកំណត់នូវលក្ខខណ្ឌពាក់ព័ន្ធជាមួយការភ្ជាប់ចរន្ត ការដំណើរការការប្រើប្រាស់ ការកត់ត្រាបរិមាណប្រើប្រាស់ ការទូទាត់ ព្រមទាំងអាណត្តិនៃការទិញលក់។ កិច្ចព្រមព្រៀងនេះត្រូវគោរពទៅតាមបទប្បញ្ញត្តិ កូដ នីតិវិធី និងសេចក្តីណែនាំនានារបស់អាជ្ញាធរអគ្គិសនីកម្ពុជា។ ចំពោះតំបន់ចែកចាយនីមួយៗរបស់អ្នកលក់ផ្ទាល់ ដែលបានភ្ជាប់ជាមួយអនុស្ថានីយរបស់បណ្តាញជាតិបញ្ជូនអគ្គិសនី ហើយបានយកប្រភពអគ្គិសនីពីអនុស្ថានីយ ថ្លៃនៃប្រភពអគ្គិសនីដែលតំបន់ចែកចាយនីមួយៗបានយកពីប្រព័ន្ធបណ្តាញជាតិបញ្ជូនអគ្គិសនីនោះ ក៏ត្រូវគិតតាមលក្ខខណ្ឌភ្ជាប់ និងអត្រាថ្លៃដែលបានកំណត់ក្នុងបញ្ជីថ្លៃលក់នេះដែរ។

## ខ-លក្ខខណ្ឌសម្រាប់ការភ្ជាប់ចរន្តពីទ្វាចរន្តតង់ស្យុងមធ្យមអនុស្ថានីយ

អនុស្ថានីយទាំងឡាយ ដែលមានគោលដៅផ្តល់ប្រភពអគ្គិសនីឲ្យអ្នកទិញ ដែលជាអ្នកបញ្ជូនរង ឬអ្នកចែកចាយអគ្គិសនីបន្ត តែងមានត្រង់ស្វូបញ្ចុះតង់ស្យុងពីតង់ស្យុងខ្ពស់មកតង់ស្យុងមធ្យម និងមានទ្វារចរន្តតង់ស្យុងមធ្យមមួយចំនួនសម្រាប់ផ្តល់ប្រភពអគ្គិសនីតាមតង់ស្យុងមធ្យមឲ្យអ្នកទិញ ។ បរិក្ខារទ្វារចរន្តតង់ស្យុងមធ្យមនៅអនុស្ថានីយបណ្តាញជាតិទាំងអស់ គឺជាកម្មសិទ្ធរបស់អ្នកលក់ និងឋិតនៅក្នុងបញ្ជីអចលនទ្រព្យរបស់អ្នកលក់ ដែលពុំអាចទាមទារឲ្យអ្នកទិញជាអ្នកវិនិយោគបានឡើយ ។ ការអនុញ្ញាតឲ្យអ្នកទិញភ្ជាប់ចរន្តផ្ទាល់ពីទ្វារចរន្តតង់ស្យុងមធ្យមនៃអនុស្ថានីយ ត្រូវធ្វើជាទូទៅ ដោយមិនមានការរើសអើង ឲ្យតែអនុស្ថានីយនោះមានអានុភាពសល់ និងមានទ្វារចរន្តនៅទំនេរ និងឲ្យតែអ្នកទិញនោះគោរពទៅតាមលក្ខខណ្ឌ ដូចខាងក្រោម ៖

លក្ខខណ្ឌភ្ជាប់ ៖ អនុញ្ញាតចំពោះអ្នកទិញ ដែលមានអាជ្ញាបណ្ណស្របច្បាប់ពីអាជ្ញាធរអគ្គិសនីកម្ពុជា។ អ្នកទិញដែលត្រូវបានអនុញ្ញាតឲ្យស្នើសុំភ្ជាប់ចរន្តពីទ្វាចរន្តអនុស្ថានីយផ្ទាល់មាន ៖ ១-អ្នកទិញដែលផ្គត់ផ្គង់ឲ្យតំបន់ចែកចាយច្រើន និងមានអានុភាពត្រូវការប៉ាន់ស្មានក្នុងរយៈពេល៥ឆ្នាំទៅមុខមិនតូចជាង៥មេហ្គាវ៉ាត់ និងមានខ្សែបណ្តាញបញ្ជូនរងគិតពីអនុស្ថានីយទៅដល់ព្រំដែននៃតំបន់ចែកចាយណាមួយមិនតិចជាង ២០គីឡូម៉ែត្រ ២-អ្នកទិញផ្គត់ផ្គង់ឲ្យតំបន់សេដ្ឋកិច្ចពិសេសឬតំបន់ឧស្សាហកម្ម ដែលមានអានុភាពត្រូវការប៉ាន់ស្មានក្នុងរយៈពេល៥ឆ្នាំទៅមុខមិនតូចជាង៥មេហ្គាវ៉ាត់(ករណីនេះមិនមានកំណត់ប្រវែងខ្សែបញ្ជូនរងទេ) ៣-តំបន់ចែកចាយអគ្គិសនីធំៗដែលជាតំបន់ទីក្រុង និងតំបន់ទីរួមខេត្ត ដែលមានអានុភាពត្រូវការប៉ាន់ស្មានក្នុងរយៈពេល៥ឆ្នាំទៅមុខមិនតូចជាង៥មេហ្គាវ៉ាត់ ៤-តំបន់ចែកចាយអគ្គិសនីជនបទដែលមានទំហំអានុភាពត្រូវការធំប៉ាន់ស្មានក្នុងរយៈពេល៥ឆ្នាំ ទៅមុខ មិនតូចជាង៥មេហ្គាវ៉ាត់ និងមានផ្ទៃដីចែកចាយធំដែលខ្សែបណ្តាញបញ្ជូន MV គិតពី អនុស្ថានីយទៅដល់ត្រង់ស្វូណាមួយ មានចម្ងាយលើសពី២០គីឡូម៉ែត្រ។

លក្ខខណ្ឌប្រើប្រាស់ ៖ អានុភាពចុះកិច្ចសន្យាមិនតូចជាង៥មេហ្គាវ៉ាត់។ ដោយសារការផ្តល់ប្រភពអគ្គិសនីនេះគឺជាការផ្តល់ឲ្យទៅអ្នកកាន់អាជ្ញាបណ្ណ ដែលគ្រាន់តែមានភារកិច្ចបញ្ជូនអគ្គិសនីបន្តទៅឲ្យអ្នកប្រើប្រាស់ និងមានភារកិច្ចចូលរួមអភិវឌ្ឍន៍ពង្រីកអគ្គិសនីភាវូបនីយកម្មទូទៅ ទាំងនៅទីក្រុង និងជនបទ ដូច្នេះមិនមានការកំណត់ឲ្យជានាទិញអប្បបរមាទេ ប៉ុន្តែអគ្គិសនីកម្ពុជាមានសិទ្ធធ្វើការសិក្សាអំពីសេចក្តីត្រូវការអគ្គិសនីរបស់តំបន់ ដែលនៅក្រោមការគ្រប់គ្រងរបស់អ្នកកាន់អាជ្ញាបណ្ណរួចធ្វើការសម្រេចអនុញ្ញាតឲ្យភ្ជាប់ចរន្តពីទ្វាចរន្តអនុស្ថានីយឬទេ?។

## ២-សេចក្តីណែនាំលម្អិតក្នុងការអនុវត្តន៍បញ្ជីថ្លៃលក់អគ្គិសនី សម្រាប់ការលក់អគ្គិសនីឲ្យអ្នកទិញ ចេញពីបណ្តាញបញ្ជូនរង

### ២.១-គោលការណ៍កំណត់អត្រាថ្លៃលក់អគ្គិសនីសម្រាប់ការលក់អគ្គិសនីឲ្យអ្នកទិញ ចេញពីបណ្តាញបញ្ជូនរង

ដើម្បីផ្គត់ផ្គង់អគ្គិសនីពីបណ្តាញជាតិបញ្ជូនអគ្គិសនី ទៅឲ្យអ្នកប្រើប្រាស់នៅតំបន់ជនបទនានា គេមិនត្រឹមតែត្រូវការបញ្ជូនអគ្គិសនីនេះ តាមរយៈបណ្តាញបញ្ជូនរងមេរបស់អ្នកលក់ ប៉ុណ្ណោះទេ តែចាំបាច់ក៏ត្រូវការបញ្ជូនអគ្គិសនីនេះ តាមរយៈបណ្តាញ MV របស់អ្នកទិញនានា ទាំងអ្នកកាន់អាជ្ញាបណ្ណបញ្ជូនរង និងទាំងអ្នកកាន់អាជ្ញាបណ្ណចែកចាយផងដែរ។ ចាប់ពីខែមីនា ឆ្នាំ២០១៦ មក អត្រាថ្លៃលក់អគ្គិសនីឲ្យអ្នកទិញអគ្គិសនីពីបណ្តាញបញ្ជូនរងរបស់អគ្គិសនីកម្ពុជា និងពីបណ្តាញបញ្ជូនរងឯកជន ត្រូវកំណត់ជាអត្រាមួយឯកភាពទូទាំងប្រទេស។

### ២.២-សេចក្តីណែនាំសម្រាប់ការភ្ជាប់ចរន្តឲ្យអ្នកទិញ

បណ្តាញបញ្ជូនរងក្នុងសេចក្តីសម្រេចនេះ សំដៅបណ្តាញមេតង់ស្យុងមធ្យមរបស់អ្នកលក់ ដែលតចេញពីទ្វារចរន្តនៃអនុស្ថានីយរបស់បណ្តាញជាតិបញ្ជូនអគ្គិសនីណាមួយ ឬដែលតចេញពីចុងខ្សែនៃបណ្តាញមេតង់ស្យុងមធ្យមរបស់ប្រព័ន្ធអគ្គិសនីតំបន់ចែកចាយណាមួយរបស់អ្នកលក់ ដែលបានយកប្រភពអគ្គិសនីពីបណ្តាញជាតិបញ្ជូនអគ្គិសនី ដើម្បីផ្គត់ផ្គង់អគ្គិសនីជាលក្ខណៈដុំឲ្យអ្នកទិញ ។ ការភ្ជាប់ចរន្តពីបណ្តាញបញ្ជូនរងទាំងនេះ ត្រូវបានបើកឲ្យអ្នកទិញអគ្គិសនីទាំងឡាយណាដែលមានលក្ខណៈដូចខាងក្រោម ៖

*លក្ខខណ្ឌភ្ជាប់* ៖ អ្នកទិញដែលត្រូវបានអនុញ្ញាតឲ្យស្នើសុំភ្ជាប់ចរន្តពីបណ្តាញបញ្ជូនរងរបស់អ្នកលក់មាន ៖ ១-អ្នកកាន់អាជ្ញាបណ្ណបញ្ជូនរង និង២-អ្នកកាន់អាជ្ញាបណ្ណចែកចាយ។ អនុញ្ញាតចំពោះតែអ្នកទិញ ដែលមានអាជ្ញាបណ្ណស្របច្បាប់ពីអាជ្ញាធរអគ្គិសនីកម្ពុជាប៉ុណ្ណោះ។

*លក្ខខណ្ឌអានុភាព* ៖ ដោយសារតែការផ្តល់ប្រភពអគ្គិសនីនេះគឺជាការផ្តល់ឲ្យទៅអ្នកទិញ ដែលគ្រាន់តែមានភារកិច្ចបញ្ជូនអគ្គិសនីបន្តទៅឲ្យអ្នកប្រើប្រាស់ និងមានភារកិច្ចចូលរួមអភិវឌ្ឍន៍ពង្រីកអគ្គិសនីភាវូបនីយកម្មទូទៅ ដូច្នេះមិនមានការកំណត់ទំហំអានុភាព និងការធានាទិញអប្បបរមាទេ។

ការភ្ជាប់ចរន្តនិងការទិញអគ្គិសនីពីខ្សែបណ្តាញបញ្ជូនរងរបស់អ្នកលក់ខាងលើ ត្រូវមានកិច្ចព្រមព្រៀងទិញ-លក់អគ្គិសនី ដែលកំណត់លក្ខខណ្ឌផ្សេងៗពាក់ព័ន្ធជាមួយការភ្ជាប់ចរន្ត ការដំណើរការ ការប្រើប្រាស់ ការកត់ត្រាបរិមាណប្រើប្រាស់ អត្រាថ្លៃលក់អគ្គិសនី ការទូទាត់ ព្រមទាំងអាណត្តិនៃការទិញលក់។ អ្នកទិញអាចស្នើភ្ជាប់ចរន្តច្រើនចំណុច តាមស្ថានភាពប្រសិទ្ធភាពសេដ្ឋកិច្ច។ ការព្រមព្រៀងទិញដុំច្រើនចំណុចខុសគ្នា និងខុសប្រភេទគ្នា អាចសរុបចូលគ្នានៅក្នុងកិច្ចព្រមព្រៀងតែមួយសម្រាប់អ្នកទិញ

មួយ។ កិច្ចព្រមព្រៀងនេះ ត្រូវគោរពទៅតាមបទប្បញ្ញត្តិ កូដ នីតិវិធី និងសេចក្តីណែនាំនានារបស់អាជ្ញាធរអគ្គិសនីកម្ពុជា។

## ៣-សេចក្តីណែនាំលម្អិតក្នុងការអនុវត្តន៍ថ្លៃថាមពលរ៉េអាក់ទីវ

ក្នុងការទទួលអគ្គិសនី "អ្នកទិញ" ត្រូវរក្សាមេគុណអានុភាព (cosφ) នៃការទទួលឲ្យឋិតនៅក្នុងកម្រឹតគុណភាពcosφ≥ 0.9 ឬtgφ≤ 0.484 មានន័យថា "អ្នកទិញ"ត្រូវយកថាមពលរ៉េអាក់ទីវពីប្រព័ន្ធផ្គត់ផ្គង់របស់"អ្នកលក់"មិនឲ្យលើសពីចំនួនកំណត់មួយដែលកំណត់ដោយcosφ≥ 0.9 ឬtgφ≤ 0.484។ ក្នុងករណីដែលអ្នកទិញខកខានពុំបានរក្សាមេគុណអានុភាពឲ្យបានដូចការកំណត់ខាងលើ ដោយយកថាមពលរ៉េអាក់ទីវលើសពីចំនួនកំណត់ "អ្នកទិញ"នោះត្រូវបង់ថ្លៃបរិមាណថាមពលរ៉េអាក់ទីវ ដែលខ្លួនយកលើសពីចំនួនកំណត់តាមអត្រាថ្លៃថាមពលរ៉េអាក់ទីវស្មើនឹង 0.025$US ក្នុង១គីឡូវ៉ុលអំពែររ៉េអាក់ទីវម៉ោង (kVArh)។ បរិមាណថាមពលរ៉េអាក់ទីវដែលប្រើលើសពីការកំណត់ហើយត្រូវទូទាត់ថ្លៃនោះត្រូវគណនាតាមរូបមន្ត ៖

$W_{r2} = W_a \times ( (W_{r1} / W_a) - 0.484 )$ ដែល៖

$W_a$ ៖បរិមាណថាមពលអាក់ទីវគិតជា kWh ដែលកត់ត្រាដោយនាឡិកាស្ទង់

$W_{r1}$ ៖បរិមាណថាមពលរ៉េអាក់ទីវគិតជាkVArhដែលកត់ត្រាដោយនាឡិកាស្ទង់

$W_{r2}$ ៖បរិមាណថាមពលរ៉េអាក់ទីវគិតជាkVArhដែលប្រើលើសហើយត្រូវទូទាត់

ក្នុងករណីដែលប្រព័ន្ធប្រើប្រាស់អគ្គិសនីរបស់"អ្នកទិញ" ត្រូវការប្រើប្រាស់ថាមពលរ៉េអាក់ទីវច្រើនលើសពីការកំណត់cosφ≥ 0.9 ឬtgφ≤ 0.484 "អ្នកទិញ"នីមួយៗអាចតម្លើងកុងដង់សាទ័រ ភ្ជាប់ជាមួយបណ្តាញរបស់ខ្លួន ដើម្បីឱ្យកុងដង់សាទ័រនេះផលិតថាមពលរ៉េអាក់ទីវបំពេញបន្ថែមសម្រាប់សេចក្តីត្រូវការផ្ទាល់របស់ខ្លួន ដោយមិនបាច់យកថាមពលរ៉េអាក់ទីវពីបណ្តាញផ្គត់ផ្គង់របស់អ្នកលក់ឱ្យលើសពីចំនួនកំណត់ខាងលើឡើយ។ ក្នុងករណីដែល "អ្នកទិញ" យកថាមពលរ៉េអាក់ទីវមិនលើសពីចំនួនកំណត់តាម cosφ≥ 0.9 ឬtgφ≤ 0.484 "អ្នកទិញ"នោះមិនតម្រូវឲ្យទូទាត់ថ្លៃថាមពលរ៉េអាក់ទីវនេះទេ។

* * * * * * * * *